CAMBODIA EXPRESS NEWS

រឿង

# នារីវរជ្ឈកំចាត់គ្រឿងញៀន

## ប្រលោមលោកបែបស៊ើបអង្កេត

និពន្ធដោយ យូ បូ

### អារម្ភកថា

ដោយឃើញថានៅទស្សវត្ស៨០ ទស្សវត្ស៩០ និងនៅដើមឆ្នាំ ២០០០ ពុំទាន់ឃើញមានរឿងប្រភេទស៊ើបអង្កេត ខ្ញុំបាទក៏សរសេររឿងស៊ើបអង្កេតក្រោមចំណងជើងថា នារីវរជ្ឈកំចាត់គ្រឿងញៀន ។

រឿង នារីវរជ្ឈកំចាត់គ្រឿងញៀន ជាវីរភាពរបស់នារីខ្មែរដែលដាក់ជីវិតដើម្បីរដ្ឋ និងប្រជាជនខ្មែរ ជាភារកិច្ចដ៏ឆ្នើមរបស់មនុស្សខ្មែរដែលហ៊ានដាក់ជីវិតដើម្បី ជាតិ សាសនា ព្រះមហាក្សត្រ ។

រឿង នារីវរជ្ឈកំចាត់គ្រឿងញៀន ជារឿងដែលអ្នកនិពន្ធប្រឌិតទាំងស្រុង ។ អាស្រ័យហេតុនេះ ប្រសិនបើមានប៉ះពាល់ដល់កិត្តិយស ឬនាមឈ្មោះរបស់លោកអ្នកសូមមេត្តាខន្តីអភ័យទោស ។

ខ្ញុំបាទសង្ឃឹមថា រឿងប្រលោមលោកប្រភេទស៊ើបអង្កេត អាចនឹង រស់រានមានជីវិតនៅលើទីផ្សារនៃកម្ពុជារដ្ឋយើងពុំលែងឡើយ ។

ភ្នំពេញ ថ្ងៃទី៧ ខែមករា ឆ្នាំ២០០៧

យូ បូ

## ជំពូក១

## សិស្សសាលាចារកម្ម

កងចក្រនៃចក្រវាឡវិលទៅមុខ កងចក្ររបស់ប្រទេសកម្ពុជាក៏វិលទៅមុខដែរ ។ ចំណែកឯកងជីវិតរបស់កញ្ញា នារីរដ្ឋ ០៧១ ក៏វិលទៅមុខក្នុង នាមជាអ្នកបូជាជីវិតដើម្បី ជាតិ សាសនា ព្រះមហាក្សត្រ ។

ប៉ុន្តែ កងជីវិតរបស់នារីរដ្ឋ ពិតជាកងដែលធ្វើអំពីដែកថែប មិនស្អុយ ក្នុងភក់ជ្រាំ មិនរលាយក្នុងកំដៅភ្លើង... ។

ប៉ុង១... ប៉ុង១... ប៉ុង១... ស្នូរកាំភ្លើងផ្ទុះចេញពីមនុស្សបីក្រុម ។ នារី រដ្ឋ រមៀលខ្លួនផុតពីគ្រាប់កាំភ្លើងរបស់ក្រុមទីមួយ ហៀបនឹងងើបពីដី ស្រាប់តែ គ្រាប់កាំភ្លើងនៃមនុស្សក្រុមទីពីរ បាញ់ប្រាវមកទៀត ធ្វើឱ្យស្រស់ស្រីខឹងឆួល ។ ប៉ុន្តែភាពអត់ធ្មត់នៃដែកថែប ដែលទើបនឹងលត់អស់រយៈពេល៦ឆ្នាំ នៃសាលាចារកម្ម បានធ្វើឱ្យនារីរដ្ឋ ផ្តេកខ្លួនផ្ទឹបនឹងគល់ស្រល់ ។ មើលន៎ ! ខ្លួនដេក ផ្ងារ ប្របនឹងគល់ឈើ តែដៃកាន់អាវុធរេជោប់ជានិច្ច ពន្លឺភ្នែករេដូចសត្វខ្លារកចំណី ត្រចៀកទាំងទ្វេររេកស្នូរចំឡែក ។ អស់អ្វីជាឧបសគ្គហើយ ប៉ុន្តែគំនិតប្រតិកម្មនៃសាលាចារកម្ម បានរុញដងកាយដ៏ស្រស់ស្រឡូន រាងសង្ហាដូចរាជសីហ៍របស់នាង ឱ្យងើបឈរត្រង់នឹងដើមស្រល់រួចហើយ ភ្លែត ! ភ្លែត ! ក្នុងដំណើរខ្លាញីវែងចង្កេះ នាងប្តូរទីកន្លែងពីដើមស្រល់មួយទៅដើមស្រល់មួយ ស្រាប់តែ ប្រាវ ! ប្រាវ ! មកទៀត នារីឆ្លៀត បង្អាញខ្លួន ភុច ! គ្រាប់កាំភ្លើង មួយគ្រាប់ទម្លុះកំភួនដៃនាង ។ នារីរដ្ឋ ខាំមាត់នៅស្ងៀម សងទៅវិញ ប៉ុង ! ម្ចាស់អាវុធដែលបាញ់នាងរបួសកដៃធ្លាក់អាវុធទៅដី សំដី ស្រែកអូយ ! ។ ភ្លាមនោះ សំឡេងអាវុធក៏ស្ងប់ កញ្ញារត់រំដោះខ្លួនផុតពីលានប្រយុទ្ធ ស្រាប់តែ វឹប ! វឹប ! ទម្ងន់ជើងរបស់បុរសម្នាក់វឹធមករកក្បាលនាង និងចង្កេះនាង ។ នាងគេចផុតហៀបសងទៅវិញ ស្រាប់តែនាងឃើញលោកអគ្គនាយកនគរបាលញញឹមស្រស់បង្ហោះវាចា :

-ឈប់សិន អារដ្ឋ ! ខ្ញុំទេ !

ហាស់ ! ហាស់ ! លោកអគ្គនាយកខ្លាចដែរតើ !

ប្រសិនបើខ្លាញីនេះមិនទប់ទាន់ទេ ប្រហែលជា៦ជើង ផ្ទួនរបស់នារី រដ្ឋ ធ្វើឱ្យលោកអគ្គនាយកសំរាន្តពេទ្យបីខែយ៉ាងតិច ។

មាណវី ញញឹមបណ្តើរបង្ហើបវាចា :

-យីចៅហ្វាយ ! លោកអញ្ជើញមកដែរ ?

លោក សំរង សាឌី ប្រធានអគ្គនាយកនគរបាលជាតិបញ្ជាក់ :

-ខ្ញុំគឺអញ្ចឹង ! ខ្ញុំចូលចិត្តធ្វើអ្វីដែលប្រាកដ ដែលជាក់ស្តែង បើខ្ញុំមិន មកទេ តើធ្វើម៉េចនឹងដឹងថា នារីរដ្ឋ មានថ្វីដៃប៉ុណ្ណានេះ !

មាណវី បញ្ចេញទឹកមុខម៉ឺងម៉ាត់បញ្ជាក់តបវិញ :

-ខ្ញុំដឹងថាលោកមិនត្រឹមតែមកមើលផ្ទាល់ទេ គឺលោកមានផែនការ មួយចង់ប្រើខ្ញុំទៀតផង !

លុះសួរត្រង់ដូច្នេះ លោកអគ្គនាយកធ្វើមុខអេះអុញ ។ ស្រស់ជីវីសួរ បន្ថែម :

-យ៉ាងម៉េច ? មែនឬទេ ?

លោកអគ្គនាយកងក់ក្បាលទាំងញញឹមស្រស់ស្រាយ រួចពោលបញ្ជាក់ :

-មែនហើយ តែខ្ញុំនឹងប្រាប់នាងនៅលើឡាន ព្រោះជាការសម្ងាត់ ។ ល្ងាចនេះខ្ញុំអញ្ជើញនាងទៅញ៉ាំបាយមួយពេលជាមួយអស់លោកនាយកការិ យាល័យពីរ-បីរូបទៀត ។ តែនាងជិះឡានជាមួយ ខ្ញុំតែពីនាក់ប៉ុណ្ណោះ ។

មាណវី ញាក់មុខសំឡឹងមុខលោកនាយក :

-តើលោកនាយកប្រាប់លោកស្រីហើយឬនៅ ?

លោកនាយកសំឡឹងមុខនាងយ៉ាងម៉ឺងម៉ាត់ ក្នុងទឹកមុខជាចៅហ្វាយ :

-កុំនិយាយលេង ! នេះគឺជារឿងជាតិ ហើយគឺជារឿងគ្រោះថ្នាក់ដល់ នាងផង !...

លោកនាយកពោលពុំទាន់ចប់ ពួកមនុស្សបីក្រុមក៏ដើរមកដល់ មានទាំងបុរសម្នាក់រុំដៃ ដោយចងយួរពាក់នឹង-ក មានពេទ្យម្នាក់ដើរអមជាមួយ ។ លោកនាយកសួរយ៉ាងបន្ទាន់ :

-ម៉េចទៅលោកថាន ដៃលោកមិនធ្ងន់ធ្ងរទេឬ ?

គ្រូពេទ្យឆ្លើយបញ្ជាក់ :

-ធ្ងន់ដែរព្រោះរយៈសាច់មួយដុំ ។

គ្រូពេទ្យឆ្ងល់ស្រែកទាំងមិនធម្មតាមកកាន់នារីរដ្ឋ :

"ហាក់ ! អម្បាញ់មិញលោក ថាន ថាបាញ់នាងត្រូវកំភួនដៃ រួចចុះ ម៉េចក៏នាងនៅធ្វើព្រងើយអញ្ចឹង ?"

លោកនាយកបែបភ័យក៏ចាប់ដៃនាងមើល :

-ថាម៉េច ? នាងត្រូវគ្រាប់មែន ?

ឆោមជីវិតលូកដៃក្នុងហោប៉ៅយកកំភួនដៃមួយទាំងមូល មានទាំងម្រាមដៃ និងមានឈាមប្រឡាក់កំភួនដៃយកមកបង្ហាញ គេទាំងអស់គ្នា ធ្វើឱ្យអ្នកខ្លះស្រែកយី ! ហាក ! ដោយក្តីងឿងឆ្ងល់ ។ ស្រស់ជីវីបញ្ជាក់ឱ្យអស់អល់អែកថា :

-នេះជាកំភួនដៃសិប្បនិម្មិត ខ្ញុំមិនត្រូវយកវាមកប្រើក្នុងពេលដែល យើងហ្វឹកហាត់បែបនេះទេ ប៉ុន្តែក្នុងកម្មវិធីហ្វឹកហាត់របស់យើងគឺអស់លោក ព័ទ្ធបាញ់តែ១៥នាទីប៉ុណ្ណោះ ។ ក្រោយមកស្រាប់តែថែម ១០ នាទី ហើយ១០ នាទីទៀត ជាពិសេសក្រុមទីបីនេះ ខ្ញុំមិនស្គាល់មុខផង ខ្ញុំខ្លាចក្រែងសត្រូវមកបន្លំ ខ្ញុំក៏ប្រើវាទៅ ។

ពោលរួចនាងច្របាច់កំភួនដៃធ្វើអំពីកៅស៊ូនេះឱ្យនៅតូច រួចដាក់ចូល ក្នុងហោប៉ៅ ទើបងាកទៅលោកថាន :

-សូមលោកអភ័យទោស ខ្ញុំគ្មានបំណងធ្វើឱ្យលោករបួសទេ គឺខ្ញុំបាញ់ បំបែកដងកាំភ្លើងរបស់លោកតែ ។

លោកម្នាក់ឈរក្បែរនោះ លើកកាំភ្លើងបង្ហាញ :

-អស្ចារ្យណាស់ ! ពិតជាអស្ចារ្យមែន ! កាំភ្លើងរបស់លោក ថាន បែកបន្ទះឈើនៅលើដងទៅហើយ !

លោកនាយកម្ចីម្នាពោលកាត់ :

-មិនអីទេ រឿងនេះខុសពីខ្ញុំទេ ! ដោយសារខ្ញុំចង់ដឹងពីសមត្ថភាពរបស់នាង ទើបខ្ញុំប្រើពីរក្រុមទៀតឱ្យមកស្កាត់បាញ់នាង ហើយទីបំផុតគឺខ្ញុំតែម្តង ប្រសិនបើនាងទប់ដំណើរជើងមិនទាន់ទេ ប្រហែលជាខ្ញុំត្រូវដេកពេទ្យពុំខានឡើយ ! ។

បន្ទាប់មក ក្រុមហ្វឹកហាត់ទាំងអស់គ្នា ដោះខោអាវគ្រោះចេញ ទើប នាំគ្នាឡើងឡានចុះពីភ្នំគីរីរម្យ ។

## ជំពូក២

## ផ្លូវទៅជួបមច្ចុរាជ

រថយន្តឡិនគ្រីស័រដ៏តូចច្រឡឹងម៉ូត ១៩៩៩ ក្រោមបញ្ជារបស់នារីរដ្ឋ បានបោះពួយក្នុងល្បឿនទៅជួបយមបាលកំពុងឆ្លងកាត់ក្រុងបាត់ដំបង ក្នុងគោលដៅឆ្ពោះទៅប៉ោយប៉ែត... ក្ដាំង ! រថយន្តនេះធ្លោលកណ្តាលទ្រូងព្រៃ ។ ស្រស់ស្រីដេកស្ទ្បាបក្បែរគល់ឈើ ក្រុមអ្នកបាញ់បេ-៤០ បីនាក់ ឈររលាក់ក្នុងសំណើចយ៉ាងគាប់ចិត្ត ។ គេបង្អង់បន្តិចទើបហ៊ានដើរចូល ព្រោះគេដឹងថា ខ្លាញី នារីរដ្ឋ រហ័សជាងរន្ទះទៅទៀត ហើយមានល្បិចកលជាងខ្លាញី ១០០ដង ។

ចំណែកធីតាដេកស្ងាត់ឈឹងក្នុងលំនឹងចាំយមបាលកាត់ក្ដីឱ្យស្លាប់ ឬឱ្យរស់។ មែន ! គំនិតប្រតិកម្ម ត្រចៀកឆ្មាព្រៃ មានអីយមបាលហ៊ានកាត់ទោស ។ ផាំង ! ផាំង ! បុរសពីរនាក់ដួល ខ្ពោក ! ខ្ពោក ! លែងដកដង្ហើម។ ផាំង ! ផាំង ! ពីរគ្រាប់ទៀត ធ្វើឱ្យអ្នកទីបីបាក់ដៃ និងបាក់ជើង ព្រោះឆវី ត្រូវការវា ទាំងរស់ដើម្បីជីវិតយកពត៌មាន ។

នារីរដ្ឋ រលាស់វាចាដោយញញឹម :

-ម៉េចទៅបងប្រុស ! ចៅហ្វាយឯងជានរណាដែរ ?

ក្នុងរបួសធ្វើឱ្យពិការដៃ-ជើង ឈឺផ្សាស្ទើរសន្លប់ តើអ្នកខ្មាញ់ប៉ុនណា ប៉ុន្តែនេត្រាស្គាល់ជាក់ជានារីដៃត្រង់ក្នុងពិភពចារកម្ម តើមិនឆ្លើយបានទេ ។ អ្នកកម្លោះញ័របបូរមាត់ :

-បាទ !... បាទ !... ខ្ញុំបាទឥតស្គាល់ទេ !

ឆវីសួរបន្ថែម :

-ឥតស្គាល់ចៅហ្វាយក៏បានដែរ តែនរណាប្រើពួកឯងឱ្យមកសម្លាប់ យើង ?

-បាទ !... បាទ !... ខ្ញុំឥតដឹងទេ !

-បាន ! អត់ដឹងក៏បានដែរ តែខ្ញុំក៏មិនអាក្រក់ណាស់ណាដែរ ។

ពោលរួចឆោមស្រស់យកកូនដបតូចមួយពីក្នុងហោប៉ៅ មកដកឆ្នុកចេញរួចចាប់ច្របាច់មាត់អ្នកកម្លោះបញ្ច្រកថ្នាំចូលមាត់វា ព្រមជាមួយវាចា :

-ខ្មែរគឺប្រើថ្នាំខ្មែរ ថ្នាំនេះធ្វើពីប្រទាលបួនមុខ គឺជូរ ល្វីងប្រហាត និង ក្ដៅ ។

ពោលពុំទាន់ផុតពីមាត់ស្រួលបួលផង អ្នកកម្លោះក៏ប្រកាច់ដោយក្ដៅអន្ទះអន្ទែង ហើយធំក្លិនស្អុយពេញខ្លួនវា ។ ឆោមឆវីយកកូនកន្សែងខ្ទប់ច្រមុះ ព្រោះខោវាទទឹកជោកដោយអាហារចាស់ ។

ភ្លាមនោះម៉ូតូហោះមួយបានមកដល់ ម្ចាស់វាឈរត្រង់ជើង គំនាប់ :

-សូមគោរពចៅហ្វាយ ! ខ្ញុំត្រេកអរណាស់ ដែលចៅហ្វាយឥតត្រូវ របួស !

ឆោមស្រស់ពោលដោយស្មោះត្រង់ :

-ឯងស្គាល់ចិត្តយើងស្រាប់ហើយ កុំគាប់សួរច្រើនពេក ក្នុងបេសក កម្ម គេមិនត្រូវឱ្យខាតពេលវេលាក្នុងការគាប់គួរពេកទេ ។

ចប់វាចា ជីវ៉ា សួរទៅអ្នករបួស :

-យ៉ាងម៉េចហើយ ល្មមប្រាប់ការពិតបានទេ ?

អ្នករបួសទន់ខ្លួនដេកដកដង្ហើមថ្លឹក១លើដី ស្រដីទាំងអស់សង្ឃឹម :

-បាទ !... បាទ !... គឺ... ព្រះតេជគុណអនុខេត្ត !

-ហ៊ឹះ! ដល់ថ្នាក់នេះផង ! មិនខុសពីការគិតរបស់យើងមែន ។ ពោលរួច ឆោមឆើតលោតឡើងលើម៉ូតូហោះបញ្ឆេះម៉ាស៊ីនង៉ោង ។ ម្ចាស់ម៉ូតូហក់រំ ! អង្គុយពីក្រោយឱបចង្កេះចៅហ្វាយស្រី ។ ខ្វះតែមួយនាទី អ្នកកម្លោះត្រូវនៅក្នុងព្រៃជាមួយជនពិការ ។ នេះក៏ជាគំនិតប្រតិកម្មមួយរបស់សហការីនារីរដ្ឋ។ ព្រោះនាយដឹងថា ចិត្តនារីខ្មែរទន់សុភាព តែក្នុងបេសកកម្មនារីរដ្ឋ ចិត្តដាច់ឥតមេត្តា ព្រោះសាលាចារកម្មបំពាក់ឈាម និងបេះដូងឱ្យទៅជាដែកថែប ។ ម៉ូតូហោះក្នុងល្បឿនទៅឋាននរកកំពុងធ្លាក់ចូលជង្ហុក រួចហោះឡើងលើ ហើយនៅពេលជួបដីទួល ឬជង្ហុកជ្រៅ១ម៉ូតូនាងហោះឆ្លងតែម្ដង ។

-យីកណ្ដុំឆែប !

ឡានតាក់ស៊ីមួយបោះពួយមកពីមុខ ស្រាប់តែនាងរោទិ៍ហ្គាង៉ោង ជាន់ហ្វ្រាំងបន្តិច រួចព្រលែងឱ្យហោះឆ្លងគុម្ពោតព្រៃ បន្តដំណើរទៅមុខធ្វើព្រងើង ។ ទ្រាំពុំបានសហការីសួរថា :

-ចៅហ្វាយ ហេតុអ្វីក៏ប្រញាប់ម្ល៉េះ ?

-គឺយើងត្រូវតែទៅជួបចៅហ្វាយវាឱ្យបានមុនពេលដែលចៅហ្វាយវា បានពត៌មានថា យើងសម្លាប់ពួកវា !

ពុំទាន់ដល់មួយម៉ោងផង ម៉ូតូហោះក៏មកប្រាកដខ្លួននៅជិតផ្ទះ លោកអនុខេត្តក្រុងប៉ៃលិន ។ នារីវដ្ដយកទូរស័ព្ទពីហាសការី ចុចទៅកាន់លោក :

-អាឡូ ! សួស្ដីលោកអនុខេត្ត

សំឡេងឆ្លើយពីចុងម្ខាង :

-បាទ ! សួស្ដី តើលោកស្រីជានរណា ?

កញ្ញាស្រស់ដម្លេះវាចា :

-ហ៊ឹះ ! លោកខ្សោយមែន តែណ្ហើយខ្ញុំប្រាប់លោកតាមត្រង់ទៅចុះ ថាសហការីរបស់លោកបីនាក់ដែលយកអាបេ ទៅបាញ់ខ្ញុំនោះ វាទៅស្ថាននរក ពីរនាក់ទៅហើយ ចំណែកម្នាក់ទៀតវាពិការមកពុំរួចទេ សូមលោកចាត់គេឱ្យទៅជួយយកគ្នាមកពេទ្យផង !

-យី ! តើលោកស្រីជានរណា ? ហើយលោកស្រីកំពុងនិយាយរឿង អ្វីហ្នឹង ? ខ្ញុំពុំយល់ទាល់តែសោះ ?

-តើលោកពុំយល់ឬធ្វើជាពុំយល់ ! ខ្ញុំសុំណាត់ជួបលោកយប់នេះ នៅ ឯក្នុងផ្ទះលោកតែម្ដង !

ទូរស័ព្ទបិទ លោកអនុខេត្តភ័យស្វាយមាត់ ។ ឃើញដូច្នេះលោកជំទាវ ម៉្មីម្នាសួរទាំងស្លន់ស្លោ :

-បង ! រឿងអីហ្នឹង ម៉េចក៏ធ្វើមុខអាក្រក់មើលម្ល៉េះ ?

លោកឯកឧត្ដមមិនឆ្លើយចំសាច់រឿង បែរជាសួរដោយញ័រ :

-អង្គរក្សយើងមាននៅទេ ?

លោកជំទាវជំរាបទាំងងឿងឆ្ងល់ :

-ចាំ ! ពួកវាចេញទៅរកញុំាអ្វីឯក្រៅហើយ... រួចចុះបងមានរឿងអ្វី ប្រាប់ខ្ញុំផងមិនបានទេឬ ?

-អឺ ! អឺ ! ឱ្យគេទៅតាមពួកវាមក !

លោកជំទាវងាកទៅកាន់កូនប្រុសជំទង់ :

-កូនប្រុសម៉ាក់ ! កូនឯងទៅរក ពូភិន ពូយង់មកឱ្យឆាប់ ថាពុកឱ្យ ហៅ ។

-អូនែ៎ ! ទេ ! ទេ ! មិនត្រូវឱ្យកូនយើងចេញពីផ្ទះទេ... អូ ! នឹក ឃើញហើយ អាយកូមហៅវាទៅ !

ទាំងលោកឯកឧត្ដម ទាំងលោកជំទាវភ័យស្លន់ស្លោណាស់ ។ គ្រាន់តែ នារីវដ្ដ ទូរស័ព្ទមកលោកឯកឧត្ដមមិនទាំងធ្លាប់ស្គាល់សំឡេង និងស្គាល់មុខនារីវដ្ដផង ក៏ភ័យរន្ធត់ដល់ថ្នាក់នេះទៅហើយ តើមិនគឺលោក ឯកឧត្ដមជាអ្នកប្រព្រឹត្តបទឧក្រិដ្ឋណាមួយទេឬ ?

លោកឯកឧត្ដមលើកទូរស័ព្ទចុចហៅនរណាម្នាក់ :

-អាឡូ ! អាឡូ ! លោកវរសេនីយ៍ឯកលឿនឡើង ! អញ្ជើញមកផ្ទះខ្ញុំឱ្យលឿន ហើយនាំអង្គរក្សជំនិតមកផង ! រឿងយើងបែកការណ៍ហើយ !

ប្រាំនាទីប៉ុណ្ណោះ ឡានឡិនគ្រីស័រដ៏ទំនើបមួយបានមកប្រាកដខ្លួននៅមុខផ្ទះលោកអនុខេត្ត ។ រួចម្ចាស់ឡានចូលក្នុងគេហដ្ឋានដ៏ទំនើប ប្រក់គ្រឿងថៃ យ៉ាងស្អាតភ្លឹង ។ លោកជំទាវនៅមាត់ទ្វារផ្ទះមានប្រសាសន៍ដោយភ័យថា :

-សូមអញ្ជើញលោក ហុង ! បងចាំនៅបន្ទប់ខាងក្នុង ។

លោកហុងដើរចូលទៅក្នុងដោយមានអង្គរក្សពីរនាក់អមផង ។ ពេលនោះពូភិន ពូយង់ អង្គរក្សរបស់អនុខេត្តក៏មកដល់ ។ លោកឯកឧត្ដម អនុខេត្ត អញ្ជើញលោកហុង អង្គុយ រួចលោកពោលថា :

-ខ្ញុំមានរឿងសំខាន់ចង់ពិគ្រោះជាមួយលោក សូមលោកឱ្យអង្គរក្ស ចេញទៅក្រៅសិនចុះ !

បន្ទាប់ពីលោកហុង ឱ្យអង្គរក្សចេញផុត ។ លោកអនុខេត្តប្រែទឹកមុខ ព្រួយបារម្ភ ពោលថា :

-មុននេះបន្តិច នារីរដ្ឋ បានទូរស័ព្ទប្រាប់ថា មានប្រុសបីនាក់ដែលយកបេ៤០ ទៅសម្លាប់នាងនោះ ឥឡូវគេស្លាប់ពីរ ពិការមួយទៅហើយ !

-វាចាពុំទាន់ចប់ លោក ហុង ក៏ញោចខ្លួនរួចស្រែកឮៗថា :

-អាប៉ែ ! មកណេះ !

ភ្លាមនោះ អាប៉ែ ចូលមកដល់ លោក ហុង និយាយតិចៗ :

-ឯងទុកអា គ្រឹះ ឱ្យនៅទីនេះការពារអញ ចំណែកឯងត្រូវរកអាផត ហើយជិះម៉ូតូទៅមើលអាព្រិត ដែលត្រូវគេបាញ់ឱ្យពិការនោះ ឯងគិតលៃយ៉ាង ណាបំបិទមាត់វាទៅ !... ម៉េចយល់ទេ ?

-ប្របាទម្ចាស់យល់ហើយ !

ណាយ គ្រឹះ ចេញផុត លោកអនុខេត្តពោលតិចៗ :

-នារីរដ្ឋ ថែមទាំងណាត់ជាមួយខ្ញុំទៀតថា នៅយប់នេះនាងនឹងមក ជួបខ្ញុំនៅក្នុងផ្ទះខ្ញុំតែម្តង ។

លោក ហុង គិតដោយព្រួយបារម្ភ មួយសន្ទុះទើបធ្វើឫកជាលើកទឹក ចិត្តលោកអនុខេត្ត :

-ហាស់ ! ហាស់ ! សូមឯកឧត្តមទុកចិត្តចុះ នារីរដ្ឋ មិនអាចប៉ះពាល់ រោមជើងលោកម្ចាស់បានទេ !

លោកឯកឧត្តមសួរ :

-ហេតុអ្វីបានជានាងនោះដឹង ហើយហេតុអ្វីបានជា ប្រុសបីនាក់ មាន អាវុធគ្រប់ដៃ សម្លាប់នាងមិនបាន ?

លោក ហុង គិតមួយសន្ទុះទើបពោល :

-ហ៊ឺ ! គួរឆ្ងល់ណាស់ ។ ឮថា នាងទើបនឹងមកពីសាលាចារកម្មនៅសហរដ្ឋអាមេរិក ។ ហេតុនេះទើបខ្ញុំឱ្យអាបីនាក់ប្រើសុទ្ធតែអាវុធធុនធ្ងន់ មាន បេ៤០ ជាដើម... ហេតុអ្វីបានជាធ្វើវាមិនបែក !... ឥឡូវនេះវាមកដល់ច្រមុះទៀត តែយើងមិនអាចហិតក្លិនដឹងថា វានៅកន្លែងណា ?

លោក ហុង បង្អង់ឈប់គិតមួយសន្ទុះទើបបន្ត :

-ឥឡូវយើងត្រូវប្រើកម្លាំងក្រោមបង្គាប់របស់យើងឱ្យស្លៀកស៊ីវិល តាមឃ្លាំមើលគ្រប់កន្លែងកំសាន្ត និងគ្រប់ភោជនីយដ្ឋានតូចធំ បើសង្ស័យនារី ណា ចាប់នារីនោះទៅកន្លែងយើងសួរចម្លើយ !... ចាំមើល៍ តើវាទ្រាំនឹងខ្សែ ភ្លើងបានឬទេ ?

នៅចម្ងាយពីផ្ទះលោកឯកឧត្តមអនុខេត្តប្រហែលម្ភៃម៉ែត្រ ។ នារីរដ្ឋ និងសហការីបានឃើញភ្ញៀវដែលចេញចូលផ្ទះរបស់លោកទាំងអស់ ។ ចំពោះ នារីរដ្ឋ អ្នកដែលនាងឃើញទាំងប៉ុន្មានសុទ្ធតែស្ថិតនៅក្នុងប្រអប់ខួរក្បាលរបស់ នាងទាំងអស់ ។ នាងខ្សឹបសហការីថា :

-លោក រិទ្ធ ! យើងត្រូវបំបែកគ្នា ហើយត្រូវប្រុងប្រយ័ត្នគ្រប់បែបយ៉ាង ម្យ៉ាងទៀតលោកត្រូវទៅរកលោកសាធឱ្យបំពេញភារកិច្ចនេះផងដែរ ។

លោករិទ្ធ ឆ្លើយតិចៗ "បាទ ! បាទ !" ។

## ជំពូក៣

## មិនស្ទួយក្នុងតក់ជ្រាំ

-ក្នុងចលនាផ្លេកបន្ទោរ ប្រាំនាទីក្រោយមក នារីរដ្ឋ ក្លាយទៅជាអ្នក បើកក្បាលដបនៅក្នុងភោជនីយដ្ឋានតូចមួយ ។ ចំណែកលោក វិទ្ធ ស្លៀកខោអាវកញ្ចាស់អ្នូសរទេះសាមឡ (រទេះដឹកមនុស្ស) មកដេកជាមួយអ្នកអូសរទេះសាមឡពីរ-បីទៀត នៅចម្ងាយប្រហែលសាបសិបម៉ែត្រពីផ្ទះរបស់លោក ឯកឧត្តមអនុខេត្ត ។

ក្នុងសំលៀកបំពាក់ស៊ីវិល លោក ហុង និងអង្គរក្សជំនិតបីនាក់ ចូលក្នុងហាងស៊ីផឹក។ នារីរដ្ឋ ស្គាល់ជាក់អង្គរក្សពីរនាក់ និងលោក ហុង ។ ឥឡូវឃើញជនថ្មីថែមម្នាក់ នាងក៏សំគាល់ជាក់ថែមទៀតដែរ ។

ថ្វីត្បិតតែឈាម និងបេះដូងរឹងដូចដែកថែប តែដើម្បីបុព្វហេតុជាតិ នាងទន់ភ្លន់ម្ចិកម្ចុក់ដូចនារីឡង់សេពិត១ :

-ចាំ ! លោកម្ចាស់អញ្ជើញពិសាអ្វីទាន !

អង្គរក្សថ្មី ជាជនល្មោភស្រីចាប់កាន់ដៃនាងភ្លាម។ នាងញោចខ្លួនបន្តិច តែបែរជាឱនមកកាន់តែជិតចោលក្លិនក្រអូបនៃភាពជាស្រីក្រមុំ ធ្វើឱ្យអង្គរក្សនេះភ្ញាក់កន្ត្រាក់អស់អង្គកាយសម្លឹងនាងដោយឥតព្រិចភ្នែក ។ លោក ហុង ឱនមកជិតធំក្លិន ភាពប្រហើររបស់ស្រស់ស្រីធ្វើឱ្យលោករំភើបក្នុងបេះដូង លោកខំដកដង្ហើមមួយខ្សឹតយ៉ាងវែងបន្លំស្រូបយកក្លិនក្រអូបរបស់ស្រី ក្រមុំមកទុកក្នុងក្រអៅបេះដូង។ ទ្រាំពុំបានលោក ហុង ពោល :

-អាមុំអាំ ! ដាក់កៅអីអង្គុយជិតបងមកអូន ! មិនអីទេ ថៅកែនេះ ស្គាល់បងច្បាស់ណាស់ ។

ស្រីជីវាប្រាថ្នាការសម្ងាត់ក៏ទាញកៅអីមកអង្គុយជិតធ្វើឫកជាអឹម អៀន ។

-ចាំ ! លោកហៅស្រាអ្វីដែរ ?

-អូ ! មិនអីទេ ចាំបងហៅអ្នកបំរើផ្សេង ចំណែកអូនត្រូវអង្គុយនៅ ជិតបងជានិច្ចណាពៅ !

ស្រីឡង់សេម្នាក់មកដល់ លោក ហុង បញ្ជាមកស្រា អ៊ិចអូ មួយដប ។ អង្គរក្សថ្មីល្មោភស្រីខំសម្លឹង នារីរដ្ឋ ដោយមិនដាក់ភ្នែកហាក់ច្រណែនខឹងនឹងថៅហ្វាយខ្លាំងណាស់ ។ បើត្រឹមតែមិត្តភ័ក្តិអ្នកមិនឱ្យស្រស់ស្រីធ្លាក់ទៅក្នុងដៃគេឡើយ ។ ក្រោយពេលផឹកអស់ស្រាកន្លះដប ទូរស័ព្ទលោក ហុង ក៏ឱ្យសញ្ញា :

-អាឡូ !... អាឡូ ! យ៉ាងម៉េចទៅហើយ តាមដាន នារីរដ្ឋ នោះបាន អ្វីខ្លះទេ ?

លោក ហុង ឆ្លើយតបវិញហាក់លើកទឹកចិត្ត :

-អូ ! ឯកឧត្តមកុំភ័យ ! ខ្ញុំបញ្ជាឱ្យគេចូលគ្រប់ភោជនីយដ្ឋាន តូច-ធំអស់ហើយ ទោះបីជាមានស្លាបក៏ហោះមិនរួចដែរ ។

-តែ... តែ...វាអាចចូលក្នុងផ្ទះខ្ញុំតាមការណាត់ជួបរបស់វាណា ។

-ណ្ហើយ ! កុំភ័យពេកខ្ញុំឱ្យគេយាមផ្ទះលោក ៥-៦នាក់ ហើយតើ ! ឯអង្គរក្សរបស់លោកក៏នៅជាមួយលោកដែរតើ ។

ទូរស័ព្ទរួច លោក ហុង បន្ទំថើប នារីរដ្ឋ មួយខ្សឹតធ្វើឱ្យលោកវិលវល់ក្នុងអារម្មណ៍ ព្រោះក្នុងមួយជីវិតស្នេហ៍ របស់លោកពុំដែលជួបប្រទះនារីណា ដែលមានក្លិនក្រអូបប្រហើរដូចនាងនេះសោះ ។ ទ្រាំពុំបានលោកអង្វរថា :

-អាមុំ ! បងសុំអង្វរ សុំអាមុំ ទៅគេងជាមួយបងមួយយប់ណាំ !

ស្រស់ស្រីឆ្លើយដោយអៀន :

-ទេ ! សូមទោសចុះ ខ្ញុំត្រូវទៅមើលម្ដាយឈឺនៅផ្ទះ។

-អូ! អញ្ចឹងស្រួលហើយ ! ណេះបងឱ្យមួយពាន់ដុល្លារសម្រាប់ព្យាបាលម្ដាយអូន ! សូមអូនមេត្តាបងផង ! បងសូមជួបអូនតែមួយម៉ោងទេ រួចសឹមទៅមើលម្ដាយអូនចុះ !

នោមជីវិត ទម្លាក់ទឹកមុខចុះដិតដាមដោយទឹកភ្នែករលីងរលោង ។ លោក ហុង ញាត់ក្រដាសដុល្លា ១០សន្លឹកក្នុងដៃនាងផ្ទាប់ ជាមួយវាចាលួង លោម :

-កុំបារម្ភអីណាអូន ! បងធានាថា នឹងចិញ្ចឹមអូនមួយជីវិត ។ មាណវី ងក់ក្បាលយកលុយញាត់ចូលចង្កេះសំពត់ :

-ចាំ ! អរគុណលោក... អរគុណលោកណាស់ !...

លោក ហុង ហៅគេឱ្យគិតលុយរួចក៏ឱនទៅប្រាប់អង្គរក្សថា : "យើងបែកគ្នាមួយម៉ោងសិន ។ ពួកឯងត្រូវទៅទំនាក់ទំនងជាមួយពួកអស់នោះ មើល តើអាចដឹងក្លិនថា នារីរដ្ឋ នៅទីណាទេ ?"

## ជំពូក៤

## ជួបតាមសន្យា

អ្វីៗ ដែលលោក ហុង និយាយតាមទូរស័ព្ទ និងឱនខ្សឹបប្រាប់អង្គរក្ស នោះ នារីរដ្ឋ ត្រចៀកឆ្មាព្រៃសុទ្ធតែស្តាប់ឮទាំងអស់ ។ សាលាចារកម្មបានបង្រៀននាងឱ្យចេះធ្វើគ ធ្វើខ្លួត រៀនសើច រៀនយំ... ។ តែពុំបានបង្រៀននាង ឱ្យធ្វើស្រីពេស្យាទេ ឥឡូវនេះក្នុងឋានៈ ជានារីឡង់សេ ដែលជាប្រភេទមិនល្អ មួយដែរនោះ តើនាងត្រូវដោះស្រាយបែបណា ?

ក្នុងឥរិយាបទប្រព្រឹត្តិតាមមេរៀននៃសាលាចារកម្ម នាងបោះជំហានមួយៗ ។ នាងភ័យៗ មានទឹកមុខញាប់ញ័រឡើងឡានឡិនគ្រីស័រ បានមកឈប់នៅមុខផ្ទះក្បឿងតូចមួយនៅមាត់ទឹក ។ នាងស្ទាក់ស្ទើរពុំហ៊ានចុះពីឡាន ។ លោក ហុង បង្អើវាចាលួងលោម :

-អាម៉ុំអូន !... កុំបារម្ភអីណា ! ឱ្យបងបីអូនបានទេ ! ឈប់ភ័យទៅ ! បងធានាថា មិនធ្វើបាបអូនទេ !

ពោលរួច លោក ហុង លូកដៃមកបីនាង ។ ស្រស់ស្រីម្ចាស់ពោលថា :

-មិនអីទេលោក ខ្ញុំដើរបានហើយ !

គ្រាន់តែចូលដល់ក្នុងបន្ទប់ លោក ហុង ស្ទុះទាំងកម្រោលទៅថើប ញក់ញីថ្ពាល់នាង ។ នាងភ័យញ័រអស់អង្គប្រាណ ច្រានវាចាថា :

-ឈប់សិនបង ! អូនមិនស្រួលខ្លួនទេ ! អូនរងាណាស់ អូនចង់ជក់ បារីមួយដើម ដើម្បីឱ្យបាត់រងា ។

លោក ហុងសើចយ៉ាងពេញចិត្ត ហុចបារីមួយដើមឱ្យនាងព្រមទាំង លូកយកដែកកេះពីក្នុងហោប៉ៅ ។ តែស្រស់ស្រីពោលថា :

-អរគុណហើយ ! ខ្ញុំមានដែកកេះហើយ ។

ពោលរួចនាងដកដែកកេះរបស់នាងមកអុជបារីជក់ ។ បឺតបានពីរខ្សឺត នាងប្រែជាមានទឹកមុខញញឹម រួចងើបទៅជិត លោក ហុង ពោលថា :

-បាត់រងាហើយ ! បារីលោកឆ្ងាញ់ណាស់ !

ទន្ទឹមនឹងនេះ នាងក៏កេះដែកកេះលេង ។ នេះជាដែកកេះតែមួយ ។ ប៉ុន្តែវាមានគន្លឹះពីរ គន្លឹះនេះគឺថ្នាំសណ្តំបានចូលទៅក្នុងច្រមុះ លោក ហុង ទៅ ហើយ ។ លោក ហុង បើកភ្នែក សឹៗរលំគ្រេងលើពូក ។ មាណវី ញញឹម ខ្ទឹប លូកយកកូនសោឡាន និងនាមប័ណ្ណរបស់លោក ហុង មកខ្សៀក ជាអក្សរចាម អក្សរជ្វា មើលពុំយល់ ។

ពីរនាទី ឡានឡិនគ្រីស័ររបស់ លោក ហុង បានមកឈប់នៅមុខផ្ទះ លោកឯកឧត្តមអនុខេត្ត ។ នារីរដ្ឋ ក្នុងសម្រស់ខោអាវឆើតឆាយ ដើរយ៉ាង សង្ហាចូលទៅក្នុងផ្ទះលោកឯកឧត្តម ។ អង្គរក្សពីរនាក់ចូលមកដល់ នាងហុច នាមប័ណ្ណរបស់លោក ហុង ព្រមជាមួយដែកកេះ ខ្វាច់ ! ខ្វាច់ ! អង្គរក្សទាំង ពីររលំគ្រេង ។ នាងកញ្ចាចូលទៅមាត់ទ្វារបន្ទប់មួយ បន្លឺវាចាយ៉ាងស្រទន់ថា :

-សូមជម្រាបសួរលោកជំទាវ ? តើលោកជំទាវនៅទេ ? លោក ហុង ឱ្យយកសំបុត្រមកជូន !

ទ្វារបើកឡើង លេចមុខលោកឯកឧត្តមចេញមកហាមាត់រៀបសួរ ស្រាប់តែ នារីរដ្ឋ ភ្ជង់កាំភ្លើង ។

-ខ្ញុំគឺ នារីរដ្ឋ សុំលោកអញ្ជើញទៅអង្គុយនៅកៅអីទទួលភ្ញៀវសិន ។

គ្រាន់តែឮពាក្យ នារីរដ្ឋ លោកឯកឧត្តមស្ទើរលោះព្រលឹង លុះមកដល់បន្ទប់ទទួលភ្ញៀវ ឃើញអង្គរក្សពីរនាក់ដេកស្តូក លោកក៏ពោលដោយភ័យ ញ័រ :

-សុំ ! សុំ ! កុំសម្លាប់ខ្ញុំ ! ចង់បានអ្វី ឬសួរអ្វី ខ្ញុំឆ្លើយប្រាប់ទាំងអស់ ។

ស្រស់ស្រីខ្វាក់សំដីម៉ឺងម៉ាត់ :

-តើអាភៀនដែលយកមកពីថៃនៅឯណា ?

-បាទ !... បាទ !... នៅផ្ទះលោក ហុង !

-ឥឡូវលោកស្លៀកពាក់ឱ្យស្រួលបួលធ្វើអាកប្បកិរិយា ឱ្យនឹងន ទៅផ្ទះ លោក ហុង ជាមួយខ្ញុំ !

លោកឯកឧត្តមដើរចូលបន្ទប់ដំណេកដោយមាន នារីរដ្ឋ ភ្ជង់កាំភ្លើងពីក្រោយ ។ លោកយកខោអាវស្លៀកពាក់ដោយថ្នម១ ខ្លាចភរិយារបស់លោកភ្ញាក់ ។ អ្នកទាំងពីរឡើងឡាន សំដៅផ្ទះលោក ហុង ។ ទៅដល់អង្គរក្សពីរនាក់ យាមផ្ទះលោក ហុង ក៏អនុញ្ញាតឱ្យអ្នកទាំងពីរចូលក្នុបន្ទប់ទទួលភ្ញៀវ ។ ខ្វាច់ ! ខ្វាច់ ! អង្គរក្សទាំងពីរលំគ្រេងដោយសារហ្គាសដែកកេះវិទ្យាសាស្រ្ត ។ នារីរដ្ឋ អូសគេយកទៅលាក់ក្រោយកៅអីពូកវែង ។ រួចនាងខ្សឹបប្រាប់ឱ្យលោកឯក ឧត្តមហៅភរិយារបស់ លោក ហុង :

-លោកស្រី ! លោកស្រី ! ខ្ញុំអនុខេត្តសូមអ្នកស្រីភ្ញាក់ឡើង ! លោក ហុង ឱ្យខ្ញុំមកជួបលោកស្រី !

ដោយស្គាល់សំដីរបស់លោកឯកឧត្តម ភរិយារបស់លោក ហុង ក៏ភ្ញាក់ រួចបើកទ្វារបន្ទប់ចេញមក ។ ភរិយា លោក ហុង លើកដៃសំពះ :

-សូមជំរាបសួរលោក !

សំពះគួរសមរួចលោកស្រីសួរបន្ថែម :

-ចុះអ្នកនាងណោះជានរណាដែរ ?

នារីរដ្ឋសម្លឹងយ៉ាងចោះចំ ចំពោះភ្នែកលោកឯកឧត្តម ។ ដោយត្រូវ កាំរស្មីនៃភ្នែកម្រឹគរបស់នារីរដ្ឋ លោកឯកឧត្តមពោលថា :

-នាងជាឈ្មួញមកទទួលយកអាភៀន អម្បាញ់មិញនាងបានតថ្លៃគ្នា ជាមួយលោក ហុង ត្រូវរ៉ូវគ្នាអស់ហើយ !!!

ដោយឃើញកែវភ្នែកដ៏មុតហ្មត់ចត់ និងអាកប្បកិរិយាញាក់ញ័រ ពុំ ប្រក្រតីរបស់លោកអនុខេត្ត លោកស្រីពោលបង្វែងដានថា :

-កាលពីក្បាលព្រលប់ ប្តីខ្ញុំយកអាភៀននោះទៅឱ្យគេហើយ អ៊ីចឹងពុំ មែនយកទៅឱ្យនាងទេឬ ?

-ហាស់ ! ហាស់ ! ប្រសប់មែន ! នេះបានចំជាភរិយារបស់អ្នក រត់ពន្ធអាភៀន !

ចប់វាចា ធីតាបង្ហាញអាវុធ :

-ខ្ញុំគឺ នារីរដ្ឋ ០៧១ ថ្នាក់លើបញ្ជាឱ្យខ្ញុំបំពេញបេសកកម្មនេះ ។ អា វុធនេះគ្មានភ្នែកទេ ហើយចិត្តខ្ញុំក៏គ្មានមេត្តា គ្មានប្រណីដែរ បេសកកម្ម គឺបេសកកម្ម ។ បើនៅអែអង់ យមបាលនឹងមកដង្ហែព្រលឹងលោកស្រី យកទៅភ្លាម ។

ពោលរួចស្រស់ស្រីងាកមករកលោកឯកឧត្តម :

-លោកទាំងពីរត្រូវដើរកៀកគ្នា ចូលក្នុងបន្ទប់យកអាភៀនមកភ្លាម កុំសាកល្បងលេងល្បិចអ្វីឱ្យសោះ !

ចប់វាចា ធីតាដកអាវុធមួយទៀតមកបាញ់សំដៅដំបូលផ្ទះ លាន់ឮ ផ្លប់ ! យ៉ាងស្រាល :

-នេះគឺអាវុធផ្ទប់ដោយបំពង់ឥតសូរ បើខ្ញុំសម្លាប់អ្នកទាំងពីរ តើនរ ណាដឹងទៅ ?

ភរិយាលោក ហុង ភ័យរញ្ជួរញ័រយកកូនសោចាក់ទូទាញយកកញ្ចប់ មួយទម្ងន់ប្រហែល២០គីឡូក្រាមយកឱ្យ នារីរដ្ឋ ។ ស្រស់ស្រីយកដៃបើកកញ្ចប់មើល រួចហិតក្លិនទើបជឿថាពិត :

សូមអរគុណអ្នកទាំងពីរ ដើម្បីសុវត្ថិភាពខ្ញុំ ក៏ដូចជាសុវត្ថិភាពអ្នកទាំងពីរ ខ្ញុំសូមប្រើដែកកេះវិទ្យាសាស្ត្រនេះ ដើម្បីសណ្តំអ្នកទាំងពីរ ។ សូមកុំភ័យ តែបួនម៉ោង លោក និងលោកស្រីដឹងខ្លួនហើយ ។ អូ ! នែ៎ ! ខ្ញុំចង់ឱ្យ លោក ហុង មកជួបលោកនិង លោកស្រីដែរ តែលោក ហុង ជាមនុស្សល្មោភកាម គាត់យកខ្ញុំទៅឃុយនៅផ្ទះក្បឿងតូចមួយនៅមាត់ស្ទឹង គាត់ក៏ត្រូវ សម្រាន្តលក់បួនម៉ោងដែរ ។ ព្រមជាមួយវាចារប៉ាស់ដូចកាំរស្មី អ្នកទាំងពីររលំគ្រេង ។ នារីវដ្ត ម្ចីម្នាទាញទ្វារផ្ទះបិទជិតខ្លាចក្រែងចោរឈ្លួញចូលលួចឥវ៉ាន់ក្នុងផ្ទះគាត់ ។

សាមសិបនាទីក្រោយកញ្ចប់មួយចំនួនបានទៅដល់អង្គរក្សរបស់លោកអភិបាលខេត្ត ។ នៅលើកញ្ចប់នោះដាក់អក្សរធំៗថា "ហាមបើកមុនជួប លោកអភិបាលខេត្តនេះជាការសម្ងាត់ សូមដាស់លោកអភិបាលខេត្តឱ្យគាត់ មើលជាបន្ទាន់" ។

អង្គរក្សទទួលជំនួនរួច រវល់តែមើលអក្សរ ពូម៉ូតូឌុប បានឌុប នារីវដ្ត ចេញទៅបាត់ ។ អង្គរក្សទាំងពីរមើលមុខគ្នាឡឹងឡង់ ក៏ប្រថុយដាស់លោក ជំទាវ ។ អានអក្សររួចលោកជំទាវក៏ដាស់ស្វាមីគាត់ ។

ដោយខ្លាចគ្រោះថ្នាក់ លោកឯកឧត្តមអភិបាលខេត្តឱ្យអង្គរក្សច្របាច់មើលដឹងថាក្នុងកញ្ចប់នេះទន់ៗ ហើយហាក់ដូចជាមានប្រអប់ប៉ុនប្រអប់ឈើ គូសប្រហែលបី ។ លោកឯកឧត្តមឱ្យភរិយាគាត់ និងខ្លួនគាត់ដើរចេញទៅឆ្ងាយ ទើបឱ្យអង្គរក្សបើកកញ្ចប់ ។ ដោយគ្មានបញ្ហាអ្វី លោក ឯកឧត្តមក៏មក ពិនិត្យ :

-យី ! អាភ្សៀន !

ព្រមជាមួយនេះ លោកឯកឧត្តមយកសំបុត្រមួយមកអាន ដោយពុំចេញសំឡេង : "លោកឯកឧត្តមអភិបាលខេត្តជាទីគោរព ! ថ្នាក់លើបានឱ្យខ្ញុំមកបំពេញបេសកកម្មចាប់គ្រឿងញៀន។ ឥឡូវនេះខ្ញុំធ្វើបានសម្រេចជាស្ថាពរហើយ ។ ខ្ញុំប្រគល់អាភ្សៀននេះឱ្យ លោកជាម្ចាស់ទឹកម្ចាស់ដី ។ ឯភស្តុតាងដែល ថាអ្នកណាជាអ្នករត់ពន្ធអាភ្សៀននោះ នៅក្នុងកាសែតម៉ាញ៉េទាំងបីនេះមាន គ្រប់សព្វអស់ហើយ ។ ចំពោះគំនិតអាក្រក់ក្នុងរឿងស្រីញីរបស់លោក វរសេនីយ៍ឯក ហុង ក៏មានផតនៅក្នុងកាសែតនេះទាំងអស់ដែរ ។ ម្យ៉ាងទៀតខ្ញុំបានសម្លាប់ គេពីរនាក់ និងធ្វើឱ្យពិការម្នាក់ ក៏មានសំឡេងនៅក្នុងកាសែតនេះដែរ។ នេះជាកាសែតចម្លងជូនលោកទេ ឯកាសែតដើមនៅក្នុងនាឡិកាដៃរបស់ខ្ញុំឯណោះ ។

សូមជំរាបលាដោយគោរព... ។

## ជំពូកទី៥
## កេះខ្លួឃាតករ

ជើងយន្តហោះអាកាសចរណ៍ខេមរភូមិន្ទ បានដឹកអ្នកដំណើរពីរាជធានីភ្នំពេញ ទៅចុះសំចតនៅអាកាសយាន្តដ្ឋាន "ដនមឿង" នៃប្រទេសថៃ ។ លើកនេះយន្តហោះបានទម្លាក់ភ្ញៀវខ្មែរ និងបរទេសចំនួន តែជាង ១០នាក់ ប៉ុណ្ណោះ រួចក៏បន្តដំណើរភ្ញៀវទៅមុខទៀត ។ នារីវដ្ត ០៧១ បានចុះពីយន្តហោះយ៉ាងអាថិកំបាំងបំផុត ។ ខ្លាកំណាច៧នាក់នៃជើងកាងរបស់ឈ្មួញទុច្ចរិតថៃ បានមកបន្លំខ្លួនធ្វើជាអ្នកមកទទួលបងប្អូន ។ តែតាមពិតគឺគេមកហែកសាច់នារី វដ្ត ០៧១ ចែកគ្នាស៊ីក្នុងតម្លៃ ៧០ម៉ឺនបាត ។ គិតទៅបើសម្លាប់នារីវដ្ត បានពួកគេនឹងបាន ១០ម៉ឺនបាត ក្នុងម្នាក់ៗ ។ អ្វីដែលគួរឱ្យងឿងឆ្ងល់ចំពោះពួកគេ គឺ ភ្ញៀវចុះពីយន្តហោះ មាននារី ៤នាក់ប៉ុណ្ណោះ ម្តេចក៏រកនារីវដ្តពុំឃើញ ។ ពួកគេបានលើកទូរស័ព្ទសួរគ្នាជាញឹកញយ តែលទ្ធផលគឺសូន្យ :

-ទេ អាសិត ! អញមើលរូបថតចាំច្បាស់ណាស់ណា៎ ! ទោះបីជានាង បន្លំខ្លួនក្នុងសភាពជាបុរសម្នាក់ ឬពាក់ពុកមាត់-វ៉ែនតាខ្មៅ ក៏នាងពុំអាចគេចផុតពីភ្នាក់ងារត្រួតពិនិត្យប៉ាស្ព័របានដែរ !

ម្ចាស់ខ្លួនឈ្មោះ សិត ឆ្លើយតាមទូរស័ព្ទមកវិញថា :

-មែនហើយ អាថេត! អញគិតថា សូម្បីតែមូស ឬ សង្កើចក៏មិនអាចគេចផុតពីកណ្ដាប់ដៃពួកយើងដែរ... ហ៊ឺ... ! ឥឡូវរលាយអស់ហើយ... នារីរដ្ឋ ០៧១ ស្អីគេនោះពិតជាអាថិកំបាំងមែន !

៥នាទីក្រោយមក ពួកគេមួយចំនួនបានមកជួបជុំគ្នានៅមុំឡានតាក់ស៊ី ។ ម្នាក់មាឌធំខ្មៅបញ្ចេញសំឡេងដោយកំហឹង :

-ហ៊ឺះ! បរាជ័យរបស់យើងលើកនេះជាបរាជ័យជាលើកទីមួយក៏ពិតមែន តើយើងមានមុខមាត់ឯណាទៅជួបពួកថៅកែ៧ទៀតទៅ?...

បុរសម្នាក់ពោលកាត់ :

-សុំទោសបងធំ ! នេះពុំមែនជាកំហុសរបស់ពួកយើងទេ ! តាមពិត នាងពុំមែនមកក្នុងជើងយន្តហោះនេះទេដឹង ?

បងធំឆ្លើយថា :

-ពិតជាមក ព្រោះក្នុងបញ្ជីអ្នកដំណើរដែលត្រូវចូលក្រុងបាងកក មានតែ ១៥នាក់ប៉ុណ្ណោះ ។ ឯឈ្មោះដើមរបស់នាង នារីរដ្ឋ ០៧១ សេដ្ឋា-ទេវី ក៏មានឈ្មោះក្នុងបញ្ជីនេះដែរ ។

ភ្លាមនោះ បុរសសង្ហាម្នាក់រត់ទាំងត្រហេបត្រហបមកដល់ :

-បងធំ ! ខ្ញុំជួបអ្នកពិនិត្យប៉ាស្ព័រហើយ គឺឃើញភ្ញៀវតែ ១៤នាក់ ទេ ដែលមកឆ្លងកាត់កន្លែងត្រួតពិនិត្យប៉ាស្ព័រ !

បងធំពោលដោយអស់សង្ឃឹម :

-ចប់ហើយ ! យើងហត់អត់អំពើហើយ ! គឺនាង នារីរដ្ឋ នោះ មកជា ផ្លូវការធ្វើសហការជាមួយប៉ូលិសថៃ...

បុរសម្នាក់ពោលកាត់ :

-សុំទោសបងធំ ! អាក្លូង និងអាភុតទៅណាម៉េចមិនឃើញពួកវា ?

បងធំឆ្លើយឡើង :

-អញប្រើ អាភុត ឱ្យតាមឡានទេសចរណ៍របស់ក្រុមហ៊ុនរហូតទៅដល់អូតែល ដើម្បីស្រាវជ្រាវក្នុងអូតែល ។ ឯអាក្លូងអញឱ្យតាមឡានតាក់ស៊ី ឯកជនរហូតទៅដល់អូតែល ដើម្បីស្រាវជ្រាវដែរ... តែល្ហើយ ប្រាកដជាបានលិចផេះកណ្ដាលចង្ក្រានហើយ... ។

ភ្លាមនោះស្រាប់តែទូរស័ព្ទបងធំឱ្យសញ្ញាសំឡេងលាន់ឡើងថា :

-ម៉េចទៅ អាគ្រឹះ ! ម៉េចស្ងាត់ឈឹងដូចចោរលួចសេះអញ្ចឹង ? នាយគ្រឹះ ឆ្លើយតតាក់តតុប :

-បាទ !... បាទ ! រកឥតឃើញទេលោកម្ចាស់ ! នាងប្រាកដជាសហការជាមួយប៉ូលិសថៃហើយ ទើបមិនឃើញនាងឆ្លងកាត់កន្លែងត្រួតពិនិត្យប៉ាស្ព័រ ។

សំឡេងឆ្លើយមកថា :

-ហ៊ឺះ! អាភ្លើ ម៉េចមិនចាត់គ្នាតាមដានឡានប៉ូលិសទៅ

នាយគ្រឹះ ឆ្លើយ :

-បាទ ! បាទទាន !

ទូរស័ព្ទបិទ នាយគ្រឹះ បញ្ជាគ្នាវាឱ្យតាមដានឡានប៉ូលិសអស់បីនាក់ នៅនាយគ្រឹះ និងគ្នាវាម្នាក់ទៀតធ្វើក្បាលងឺងើដូចឆ្នាធ្លាក់ទឹក ។ នាយ គ្រឹះ រអ៊ូម្នាក់ឯងដោយក្ដីអស់សង្ឃឹម : "តើនរណាទៅស្គាល់អស់ទៅថានរណាជាប៉ូលិស ឬមិនមែនប៉ូលិសនោះ..." ។

រអ៊ូរួចបងធំបបួលកូនចៅដែលនៅសល់ម្នាក់នេះ ឡើងម៉ូតូហោះ ត្រឡប់ចូលទីក្រុងវិញ ។

ក្រឡេកមកមើល នារីរដ្ឋ០៧១ ឯណោះវិញ នាងកំពុងដោះអាវប្រុសចេញ រួចដោះសក់ប្រុសចេញរលាស់សក់ស្រីធ្លាក់មកលើស្មា បង្កើតជាសោភ័ណដ៏សង្ហានៃទឹកមុខនារីខ្មែរ ។ សហការីរបស់នាងពោលខ្សឹបមកកាន់នាងថា :

ចៅហ្វាយ ! យើងអាចទៅបានហើយ ព្រោះពួកបងធំវាទៅអស់

ហើយ ។

នារីរដ្ឋឱ្យសញ្ញាភ្នែកពោលតិចៗថា :

-ពេលនេះបងឯងនៅជាសង្សាររបស់ខ្ញុំនៅឡើយទេ ! ខ្ញុំពុំមែនជាចៅហ្វាយបងឯងទេណា៎ !

សហការីតប :

-បាទ ! ខ្ញុំភ្លេច សុំទោស !

ពោលរួច នរៈយើងដើរទៅកាន់អ្នកគ្រប់គ្រងស្ថានីយ៍សាំងសំរាប់ចាក់ យន្តហោះ :

-សូមគោរពលោក ! ខ្ញុំសូមថ្លែងអំអរគុណចំពោះលោកយ៉ាងជ្រាលជ្រៅ ដែលលោកបានជួយឱ្យសង្សារ ខ្ញុំបន្លំខ្លួនមកជាមួយឡានសាំង ។

លោកនាយកស្ថានីយ៍សាំងតបថា :

-មិនបាច់អរគុណអីទេ ! បើគ្មានបញ្ហាពីថ្នាក់លើក៏ខ្ញុំមិនហ៊ានជួយដែរ ...

លោកនាយសើចញញឹមសម្លឹងមក នារីរដ្ឋ :

-លោកបាន នារីរដ្ឋខ្មែរ ដ៏ស្រស់ស្អាតបែបនេះធ្វើប្រពន្ធ ខ្ញុំដូចជា ចង់ច្រណែនបន្តិចហើយ !

អ្នកកម្លោះតប :

-បាទទេ ! នៅជាសង្សារនៅឡើយទេ... ! សុំជំរាបលាហើយ លោក !

នារីរដ្ឋ សំពះលាលោកនាយកស្ថានីយ៍សាំងដោយបទ្ទន់ចង្កេះឱន ក្បាលតាមទម្លាប់ថៃ ។ សហការីកៀកដៃនាងបណ្តើរចេញមកដូចជាសង្សារ ពិតៗ ។ មកដល់ក្រៅនាងស្រីយកដៃច្បូតច្រមុះសហការីប្រលែងគ្នាយ៉ាងសប្បាយ ។

សណ្ឋាគារផ្កាយមាស ភ្លើងពណ៌តូចធំផ្គុំគ្នាបង្កើតបានជាឋានសួគ៌នៃពន្លឺជ្រុងខាងណោះ ភ្លើងឌីស្កូកំពុងញាក់ភ្លឹបភ្លែតហាក់ស្រែកដង្ហោយហៅភ្ញៀវថា: "សូមអញ្ជើញ ! សូមអញ្ជើញ ! សូមអញ្ជើញរាំឌីស្កូជាមួយខ្ញុំ ទីនេះជា ឋានដែលភ្លូកភ្លឹកដោយភ្លើងពណ៌ និងស្រីស្នេហ៍..." ។

មែន ! កុំថាឡើយក្មេង-ចាស់ ជាមនុស្សមានវិញ្ញាណមករាំ សប្បាយ ទីនេះ សូម្បីតែភ្លើងពណ៌ក៏ចេះរាំឌីស្កូដែរ... ព្រោះអ្វីហ្ន៎ ? ។ អូ ! ហូ ! ព្រោះ តែចំណីឆ្ងាញ់ចម្រាញ់ចេញពីធម្មជាតិមានគ្រប់សម្ផស្សមានគ្រប់ជាតិសាសន៍ មានខ្លះស្លៀកខ្លីកំប៉ិត លេចគល់ភ្លៅ និងលេចផ្សិតបង្ហាញក្បាលពោះ គួរស្រើបស្រាល តាចាស់ក្បាលត្រងោលកំពុងថើបញ្ញាក់ញី ។ ជីវីស្រស់តំលោះ វាចារំអួយ: "កុំធ្វើអញ្ចឹងបងរសើបណាស់ ..." ។ តាចាស់បម្រះសំដីតបៈ "ហ៊ុ ! ឆវីអូន ! បងចូលចិត្តតែត្រង់ហ្នឹង ព្រោះមានក្លិនធម្មជាតិ ! បងមិនចេះថើបថ្ពាល់ទេ ព្រោះថ្ពាល់សុទ្ធតែម្សៅ..." ។

តាចាស់ងើបក្បាលឡើងផ្អឹបដើមទ្រូងទៅនឹងដោះទាំងគូដ៏ព្រហើន របស់នួននាង រួចយោកដងខ្លួនទៅឆ្វេងទៅស្តាំៗតាមចង្វាក់ស្ល៊ូ ។ ក្នុងផ្លារាំជាមួយគ្នានេះនាយភុត នាយក្លូង កំពុងរាំ បណ្តើរក្រឡេកភ្នែករកមើលមនុស្ស ចម្លែកបណ្តើរ ។ ចំណែកនាយគ្រឹះ ចោលភ្នែករវាមបែបខឹងណាស់ព្រោះរក នារីរដ្ឋ០៧១ ពុំទាន់ឃើញ ។ កំពុងខឹងងុំ ព្រោះខ្លាចបាត់អាជីពជាអ្នកស៊ីឈ្នួលសម្លាប់មនុស្ស ស្រាប់តែស្រីបំរើភ្ញៀវយកក្រដាសតូចមួយមកហុចឱ្យនាយគ្រឹះ ។ នាយ គ្រឹះ លើកឡើងឃើញលិខិតសរសេរអក្សរថៃ "សូមលោកកុំក្រហល់ ក្រហាយពេក ! ខ្ញុំមកជួបលោកហើយ ! ហត្ថលេខា : នារីរដ្ឋ ០៧១" ។

ប៉ៃ ! អាស្វាងាប់រស់ឡើងវិញ ! នាយគ្រឹះ នឹករួចក៏រត់ទៅរកស្រី បំរើភ្ញៀវ អម្បាញ់មិញ ។ ចាប់ទាញស្មានាងសួរបញ្ជាក់ :

-នាង បានសំបុត្រនេះពីណាមក ?

ស្រស់ស្រីឆ្លើយថា :

-ចាំ ! ទៅបន្ទប់ខារ៉ាអូខេលេខ៤ជាន់ទី១ ! រួចហើយធីតាបង្វិលខ្លួនចេញ ។ នាយគ្រឹះចូលទៅដល់ក្នុងបន្ទប់ នារីរដ្ឋ រួចភ្ជង់កាំភ្លើងនាង ។ ស្រស់ស្រីញញឹមខ្ចីបបញ្ចេញថ្ពាល់ខួចគួរឱ្យស្ញើប តែនាយគ្រឹះពុំត្រូវការទេ គេត្រូវការតែម្យ៉ាង :

-ប្រាក់មែនទេ ! បើព្រោះតែប្រាក់សុំលោកដាក់កាំភ្លើងចុះសិនទៅ យើងអាចនិយាយគ្នាសិនបានដែរតើ ។

នាយ គ្រឹះ ភ្ជង់កាំភ្លើងបណ្ដើរដើរសំដៅទៅបន្ទប់ទឹកបណ្ដើរ ។ នាយ បើកទ្វារបន្ទប់ទឹកឃើញថា គ្មានមនុស្ស ទើបនាយមកដាក់គន្លឹះសោរ បន្ទប់ខារ៉ាអូខេ រួចនាយយកដៃមួលសំឡេងចម្រៀងខារ៉ាអូខេឱ្យឮសំឡេងតិចៗ ដើម្បីងាយស្រួលក្នុងការសន្ទនា ។ នារីរដ្ឋ រលាស់វាចាជាភាសាថៃយ៉ាងច្បាស់ឥតទាស់ :

-ម៉េចទៅទុកចិត្តបានហើយឬនៅ ? ខ្ញុំជឿថា លោកពិតជាឆ្ងល់ ថា ហេតុអ្វីបានជាខ្ញុំមកតែម្នាក់ឯង ។

នាយគ្រឹះ ធ្វើក្បាលងឺងើហួសចិត្ត ។ ពុំមែនគាត់ងឺងើហួសចិត្ត ដោយឃើញនាងមកតែម្នាក់ឯងទេ គឺគាត់ហួសចិត្តចំពោះខ្លួនឯងថាខ្លួនជាអ្នកស៊ីឈ្នួលសម្លាប់ នារីរដ្ឋ លុះជួប នារីរដ្ឋ ហើយបែរជាមិនទាន់សម្លាប់ទៅវិញ ។ នាយមួម៉ៅក្នុងចិត្តស្រែកថា :

-នាងចង់និយាយអ្វី និយាយឱ្យលឿនទៅ !

-គឺនិយាយពីប្រាក់ហ្នឹងណាំ ! ខ្ញុំសុំសន្យាថា ក្បាលអ្នកតាស៊ីរិទ្ធរបស់ ខ្មែរដែលឈ្នួញថៃទិញមកនោះ គេលក់ថ្លៃប៉ុន្មាន ខ្ញុំនឹងឱ្យលោកថ្លៃប៉ុននោះ ។

នាយគ្រឹះ គិតក្នុងចិត្តថា "ចិតសិបម៉ឺនបាត និងប្រាំម៉ឺនដុល្លារ តើអញយកមួយណា ?... ហាស់ ! ហាស់ !... ។ នាយគ្រឹះ សើចរលាក់យ៉ាងខ្លាំង ធ្វើឱ្យនារីរដ្ឋ ត្រៀមខ្លួនប្រយុទ្ធ ព្រោះនាងឆ្ងល់មិនដឹងថា តើនាយគ្រឹះ សើចពីរឿងអ្វី ។ សើចអស់ចិត្តទើបនាយគ្រឹះ ដាក់បង្គុយលើពូក តែកាំភ្លើងគេវេជាប់ជានិច្ច ។

-ឥឡូវនាងថ្នូរនឹងអ្វី ?

-គឺថ្នូរនឹងពត៌មានថា តើក្បាលអ្នកតាស៊ីរិទ្ធនៅឯណា ?

នាយគ្រឹះ ញញឹមស្រស់ :

-ចុះបើខ្ញុំ ភ នាងជឿដែរ ?

-ក្នុងប្រភពចារកម្មគេមិនខ្លាចមនុស្សភទេ ព្រោះដៃឯងកំពុងកាន់អ្វី គេក៏កាន់របស់ហ្នឹងដែរ ។

ធីតាពោលចប់ ស្រាប់តែនាយគ្រឹះស៊កកាំភ្លើងទៅនឹងចង្កេះខោ សើច រលាក់យ៉ាងស្រួល :

-តើខ្ញុំទៅយកប្រាក់នៅឯណាទៅ ?

ធីតា ចោលផ្លែញញឹម :

-លោកអាចយកជាសាច់ប្រាក់ឥឡូវនេះក៏បាន ជាស្ញែកក៏បាន ។

នាយ គ្រឹះ អេះអុញគិតបន្តិចទើបឆ្លើយ :

-ណ្ហើយខ្ញុំយកជាស្ញែកចុះ ព្រោះខ្ញុំខ្លាចប្រាក់នាងក្លែងក្លាយ ។

-បាន !

ពោលរួចនោមឆើតយកស្ញែកមកបង្ហាញនាយ គ្រឹះ :

-លោកស្គាល់ស្ញែកនេះទេ ?

នាយគ្រឹះ ក្រឡេកមួយភ្លែតតបថា :

-អូ ហូ ! ស្គាល់ច្បាស់ហើយ !

ព្រមជាមួយនេះ នារីរដ្ឋ សរសេរជាអក្សរថៃនៅលើស្អែក ចំនួនទឹក ប្រាក់ប្រាំម៉ឺនដុល្លារ រួចចុះហត្ថលេខានៅនឹងមុខនាយ គ្រឹះ ។ នាយគ្រឹះ ទទួល ស្អែក រួចសរសើរថា :

-យី ! នាងចេះអក្សរថៃបានស្អាត់ណាស់ហ្ន៎ !

នាយយកស្អែកមកមើលរួចបន្តថា :

-ឥឡូវស្អែកនៅលើដៃខ្ញុំ បើខ្ញុំមិនប្រាប់ពត៌មានដល់នាង តើនាង យល់យ៉ាងម៉េចដែរ ?

ឆោមឆើតញញឹមធ្វើព្រងើយ :

-ខ្ញុំបានប្រាប់លោករួចហើយថា ពិភពចារកម្មគេមិនខ្លាចលោកភ ទេ ។

នាយគ្រឹះ ទ្រឹងគិត ស្រស់ស្រីនារីរដ្ឋ សួរបញ្ជាក់ :

-ម៉េច ! លោកភ័យខ្លួនឬ ?

នាយគ្រឹះ ឆ្លើយដោយអល់អែកក្នុងចិត្ត :

-បាទ !... ទេ !... អត់អីទេ ! បាទ...! នែ ! ក្បាលអ្នកតាសិរិទ្ធ នៅ នឹងពួកនាគខ្មៅ តែខ្ញុំមិនដឹងថា គេទុកនៅកន្លែងណាទេ !

ឆោមឆើតបញ្ជាក់ថា :

-បានហើយ ! អរគុណលោកហើយ សូមលោកអញ្ជើញដោយសុវត្ថិ ភាពចុះ... ខបចៃឡាយ-ឡាយ !

នាយគ្រឹះបើកគន្លឹះទ្វារចាកចេញទៅ ធីតាពៅ នារីរដ្ឋ ញញឹមខ្ជឹប ។ រំពេចនោះសំឡេងទ្វារ :

-តុក ! តុក ! តុក តុក !

ស្រស់ស្រីធីតាស្រែកសួរ :

-នរណាហ្នឹង ?

សំឡេងបុរសខ្មែរម្នាក់ឆ្លើយ :

-ខ្ញុំក-៥៣ សហការីរបស់ចៅហ្វាយ !

-អញ្ជើញចូល !

ក-៥៣ ចូលដល់ក្នុង ឈរត្រង់ជើងគំនាប់ចៅហ្វាយ រួចនាងញញឹម ស្រស់ តម្លោះវាចា :

-បានហើយ ! យើងនឹងបានលទ្ធផលល្អ! ណេះផឹកប៊ីយែរសិនទៅ ។

-យ៉ាងម៉េចចៅហ្វាយ !

-គឺយើងបានស៊ីញ៉េស្អែកជាថ្នូរនឹងពត៌មានប្រាប់ពីក្បាលអ្នកតានោះអី !

ឮដូច្នេះ ក-៥៣គិតថា យើងប្រហែលជាចាញ់បោកពួកឃាតករថៃ ហើយថ្ងៃស្អែកវាបើកលុយ ហើយវាអាចវិលមកសម្លាប់ យើងវិញ... ។ ឃើញ សហការីរបស់ខ្លួនកំពុងគិតភាំង នារីរដ្ឋ ពោលថា :

-យ៉ាងម៉េច ? កុំគិតច្រើនពេក បងឯងត្រូវដឹងថាគេយកស្រូវជាច្រើន បាវទៅបាចចោលក្នុងភក់ គឺដើម្បីច្រូតកាត់យកផលណា៎ !

ក-៥៣ គិតក្នុងចិត្តទៀតថា : អូ ! ស្អែកនេះអាចជាពន្លឺ ដើម្បីចាប់ខ្លួននាយគ្រឹះ ព្រោះវាស្គាល់អ្នកមានក្បាលអ្នកតាសិរិទ្ធ... កាលណាវាចូលទៅ បើកប្រាក់ពីធនាគារយើងអាចចាប់ខ្លួនវា... ។ គិតរួចក-៥៣ នៅស្ងៀមមិន ហ៊ានសួរចៅហ្វាយស្រីពីរឿងអ្វីឡើយ ។

នៅពេលបែកគ្នា ចៅហ្វាយស្រីពោលថា :

-បងក-៥៣ យប់នេះសូមទៅផ្ទះសម្រាន្តឱ្យសុខចុះមិនបាច់យាមខ្ញុំ ទេ យប់នេះច្បាស់ជាកណ្តុរមិនដើររកចំណីឡើយ ។

# ជំពូក៦
## ដែកថែបជួបគ្នា

ស្អែកឡើង នារីរដ្ឋ០៧១ ធ្វើដំណើរលះរលាំងចូលទៅស្ថានទូត ខ្មែរ ប្រចាំប្រទេសថៃ ។ ការសន្ទនាគ្នារវាងនារីរដ្ឋ និងឯកឧត្តម ឯកអគ្គរាជទូតមានរយៈពេលតែដប់ប្រាំនាទីប៉ុណ្ណោះ ។ គឺនាងធ្វើរបាយការណ៍ពីជ័យជំនះជាជំហានទីមួយ រួចនាងប្រាប់ឯកឧត្តមពីលេខសម្ងាត់របស់នាង និងសុំឯឧត្តមវិញពីលេខសម្ងាត់របស់ឯកឧត្តម ។

ពិភពចារកម្មពិតជាពិភពអាថ៌កំបាំង ។ ពុំទាន់បានអ្វីផង នារីរដ្ឋ ហ៊ាន ប្រាប់ឯកឧត្តមឯកអគ្គរាជទូតថាៈ បានជ័យជំនះជាជំហ៊ានទីមួយហើយ ។

ចប់អារម្មណ៍មែន នារីរដ្ឋថ្លើមពាសមេឃហ៊ានយកប្រាំម៉ឺនដុល្លារទៅចាក់ចោលក្នុងភក់ តើនាងនឹងច្រូតកាត់បានអ្វីទៅហ្ន៎ ! ព័ត៌មានឥតបានប្រយោជន៍អ្វីសោះ នាងហ៊ានទិញរហូតដល់តម្លៃខ្ពស់បែបនេះ ។

ចេញពីស្ថានឯកអគ្គរាជទូត នារីរដ្ឋបានបត់ឡានខ្វាត់ខ្វែងបន្តិចរួច ចូលទៅអង្គុយក្នុងភេសជ្ជៈដ្ឋានតូចមួយនៅជិតចិញ្ចើមថ្នល់ ដើម្បីជាការងាយ ស្រួលធ្វើសកម្មភាព ។

នាង ០៧១ញ៉ាំទឹកដោះគោនៅបណ្ដើរគិតបណ្ដើរថា : គេចាក់ស្រូវចោលក្នុងភក់ ត្រូវរង់ចាំពេលវេលាប្រាំមួយខែទើបបានស្រូវច្រូត ។ ឥឡូវយើង ចាក់លុយចោលត្រូវរង់ចាំពេលវេលាប្រាំមួយថ្ងៃទើបដឹងលទ្ធផល... មិនអីទេ... ប្រាំមួយថ្ងៃមិនយូរឡើយ ។ តែបើលទ្ធផលល្អថ្ងៃនេះអាចដឹងបានហើយ... ។

នាងកំពុងតែគិតស្រាប់តែទូរស័ព្ទឱ្យសញ្ញា ។ ធីតាលើកឡើងសំឡេង ម្ខាងពោលដោយភ័យថា :

-ចៅហ្វាយស្រី ! អាគ្រឹះវាបើកលុយពីធនាគារយកទៅដោយសុវត្ថិ ភាពហើយគ្មានឃើញប៉ូលិសថៃចាប់វាទេ !

នារីរដ្ឋ០៧១ ពោលដោយឋានៈជាចៅហ្វាយ :

-បងឯងកុំភ័យ ! ពេលដើមស្រូវដុះចេញពីភក់ទើបបងឯងឃើញ សំណាប ! បានហើយ !

នារីរដ្ឋចុចបិទទូរស័ព្ទធ្វើទឹកមុខញញឹមក្នុងក្ដីសង្ឃឹម ។ ចំណែកម្ចាស់ សំឡេងដែលនាងហៅថាបងនោះគឺ ក-៥៣នេះ ជាចារបុរសខ្មែរ មានអាជីពជាថៅកែឡានតាក់ស៊ីរស់នៅក្នុងប្រទេសថៃជាង ១០ឆ្នាំ មកហើយ តែគាត់ពុំបានចូលសាលាចារកម្មធំៗនឹងគេទេ ។ លោក ក-៥៣ គឺជាជំនួយការជាភ្នាក់ងារ ស៊ើបអង្កេតព័ត៌មាន និងអ្នកចូលរួមប្រតិបត្តិការនៅពេលដែលគេហៅរក ។ ក្នុងពិភពចារកម្មសហការីរបស់នារី រដ្ឋ ០៧១ ពុំមែនមានតែ ក-៥៣ ម្នាក់តែប៉ុណ្ណោះទេ ។ ជួនកាលនៅក្នុងពេលចាំបាច់ស្រាប់តែមានសហការីជាច្រើននាក់ ចូលរួមការងារតាមការឱ្យលេខសម្ងាត់ និងពាក្យគន្លឹះពីថ្នាក់លើ ។

មែន ! ស្រស់ស្រីទើបតែនឹងបឺតទឹកដោះគោនៅអស់ស្រាប់តែ សំឡេងមួយប្លែកលាន់ឡើងក្នុងទូរស័ព្ទនាង ។ នាងសួរថា :

-លោកជានរណា ?

សំឡេងក្នុងទូរស័ព្ទឆ្លើយ :

-ខ្ញុំជាអំពិលលាស់ស្លឹកស្រស់ !

នារីរដ្ឋ សួរបញ្ជាក់ :

-អំពិលជូរមែនទេ ?

-បាទទាន !

-តើលោកមានការអ្វីឬ ?

-បាទមាន ! គឺប៉ូលិសថៃត្រៀមខ្លួនពីរក្រុម មួយក្រុមតាមដាននាយ គ្រឹះ មួយក្រុមតាមដាននាគខ្មៅ ។ ឥឡូវនាយគ្រឹះធ្វើដំណើរទៅព្រំប្រទល់ម៉ាឡេហើយ តើចៅហ្វាយមានបញ្ជាអ្វីទេទាន ! ។

ស្រស់ស្រីឆ្លើយថា :

-មាន ! គឺលោកត្រូវទៅពីក្រោយប៉ូលិសថៃ ហើយខ្ញុំក៏ទៅឥឡូវនេះ ដែរ ។

ពោលរួច នារីរដ្ឋ ក៏ចុចទូរស័ព្ទបញ្ជាឱ្យ ក-៥៣ ធ្វើដំណើរទៅព្រំប្រទល់ប្រទេសម៉ាឡេដែរ ។ នារីរដ្ឋ ញញឹមដោយកក់ក្តៅក្នុងចិត្តគិតថា: "ស្រូវចាប់ផ្តើមដុះឫសក្នុងភក់ហើយ បន្តិចទៀតវានឹងលាស់ត្រួយពេលនោះ ទើបយើងឃើញសំណាប... ។ ពេលវេលាជាសត្យានុមតិយើងមិនអាចបង្ខំវាបានទេ... ទំរាំសំណាបធំគ្រប់ខែ ទើបវាដាក់គ្រាប់រួចក្រោយមកទើបវាទុំ...រង់ចាំពេលនោះ ទើបយើងច្រូតកាត់យកផល" ។

នោមឆើតបើកឡានក្នុងល្បឿនធម្មតា ឆ្ពោះទៅកាន់ព្រំប្រទល់ដែន ថៃ-ម៉ាឡេ ។

ជាងមួយម៉ោងក្រោយមក នារីរដ្ឋ០៧១ ដែលកំពុងបើកឡានឮ សំឡេងក្នុងទូរស័ព្ទថា :

-សូមគោរពលោកចៅហ្វាយ មានអ្នកលេងមួយក្រុមបាញ់សម្លាប់ នាយគ្រឹះ បាត់ទៅហើយ ។

នារីរដ្ឋបញ្ជាថា :

-យល់ហើយ ! តែលោកត្រូវតាមដានឱ្យស្គាល់អាសយដ្ឋានរបស់ ក្រុមចោរនោះ ចោរនោះ គឺជាក្រុមនាគខ្មៅហ្នឹងឯង ។

សំឡេងក្នុងទូរស័ព្ទឆ្លើយបញ្ជាក់ :

-ទទួលបញ្ជាចៅហ្វាយ !

តែក្រុមប៉ូលិសថៃក៏តាមដានពួកនោះដែរ ។

ស្រស់ស្រីឆ្លើយតប :

-យល់ហើយ ! សុំចប់ !

ពោលរួចធីតាបិទទូរស័ព្ទ បើកឡានធ្វើព្រងើយដដែល ។ ម៉ោងជាង ១១ហើយ ធីតាឈប់ឡាននៅមុខភោជនីយដ្ឋានមួយ បំរុងចូលទៅក្នុងហាង ដើម្បីស្រស់ស្រូប ស្រាប់តែមានបុរសថៃពីរនាក់មកអមនាងជាប់ :

-នាងត្រូវតែចូលក្នុងហាងនេះ !

ស្រស់ស្រីរលាស់វាចាជាភាសាថៃតបវិញ :

-បាន !

ចូលទៅដល់ក្នុងហាងវាបញ្ជាបន្ថែម :

-សូមអញ្ជើញចូលទៅក្នុងបន្ទប់ឯណោះ ។

-បាន ! តែខ្ញុំទិញស្ករកៅស៊ូសិន ។

នៅពេល នារីរដ្ឋ ទិញស្ករកៅស៊ូ មានបុរសម្នាក់ទំនងជាកម្មករ និយាយជាពាក្យគន្លឹះដោយសំឡេងតិចៗថា :

-ប៉ៃឡា ប៉ៃឡៃ !

នារីរដ្ឋ តបវិញតិចៗ :

-ប៉ៃឡា ប៉ៃឡង !

បុរសចម្លែកងក់ក្បាលក៏ដើរវាងទៅកៀនហាងបាត់ទៅ ។ នារីរដ្ឋដើរ ចូលក្នុងបន្ទប់អមដោយបុរសថៃពីរនាក់ ។ បន្ទប់នេះពិតជាមានភាពមនោរម្យមែន។ អ្នកទាំងបីនិយាយគ្នារអូករអឺនហាក់ដូចជាសង្សារធ្លាប់ស្រឡាញ់គ្នាជាយូរមកហើយ ។ ម៉ាស៊ីនត្រជាក់ធ្វើឱ្យបន្ទប់ត្រជាក់ស្រើប ចោលក្លិនក្រអូបបណ្តាលឱ្យភ្ញៀវមានកម្លាំងគ្រប់ៗគ្នា ។ បុរសថៃម្នាក់សួរនារីរដ្ឋថា :

-អូនញុំាអី ?

នារីរដ្ឋ ពោលដោយញញឹមស្រស់ស្រាយ :

-ចាំ អូនញុំាតាមបងទាំងអស់ !

បុរសថៃបញ្ជាម្ហូបបួនមុខ និងឱ្យគេយកប៊ីយែរមកមុន ។ ស្រីឆើតធ្វើមុខម៉ឹងម៉ាត់ពោលទៅកាន់បុរសថៃទាំងពីរ :

-តើលោកជាប៉ូលិសថៃ ឬជាពួកនាគខ្មៅ ?

បុរសម្នាក់ពោលឡើង :

-ជាពួកនាគខ្មៅ ! យ៉ាងម៉េចនាងខ្លាចឬ ?

នារីរដ្ឋ ឆ្លើយដោយម៉ឺងម៉ាត់ :

-ឯងស្គាល់យើងថា ជានរណាទេ ?

-បើមិនស្គាល់ម៉េចក៏យើងបញ្ជានាងឱ្យចូលបន្ទប់នេះ

-ល្អ ! យើងកំពុងតែរកចៅហ្វាយរបស់ពួកឯង

-កុំភ័យចៅហ្វាយយើងមកដល់ឥឡូវហើយ នាងមិនឃើញថា យើង ឱ្យគេរៀបកៅអីលើសមួយទេឬ ?

-អូហូ ! យើងពិតជាដឹង

ភ្លាមនោះបុរសម្នាក់រាងចំណាស់ដើរចូលមក ។ បុរសថៃទាំងពីរឱនគោរពដោយកោតខ្លាច អញ្ជើញចៅហ្វាយឱ្យចូលអង្គុយរួច ឧទ្ទេសនាម :

-អ្នកនាង ! នេះជាចៅហ្វាយរបស់ខ្ញុំ ។

រួចនាងងាកទៅបុរសចំណាស់ :

-បាទទាន ! នាងនេះពិតជា នារីរដ្ឋ ០៧១ ហើយ !

ក្រោយពីការគោរពគួរសមទៅវិញទៅមក រួចបុរសចៅហ្វាយ នាគខ្មៅអង្គុយចុះដោយវាចាស្រទន់ថា :

-ថ្ងៃនេះខ្ញុំមានសំណាងណាស់ ដែលបានជួបអ្នកនាង ០៧១ ខ្ញុំទើប នឹងដឹងថាខ្មែរមានចារនារីម្នាក់ដ៏ល្បីល្បាញអាស្រ័យហេតុនេះទើបខ្ញុំខំស្ទាត់រកជួបនាង !

លោកប្រុសបង្អង់ឈប់, ស្រស់ស្រីធីតាកញ្ញា ០៧១ រលាស់វាចាៈ

-ខ្ញុំសូមអរគុណដែលលោកសរសើរខ្ញុំ តើខ្ញុំសុំស្គាល់ប្រវត្តិលោកផង បានឬទេ ?

លោកប្រុសញញឹមតប :

-អូបាន ! ខ្ញុំជាប្រធានក្រុមនាគខ្មៅ ខ្ញុំមកជួបនាងក្នុងបំណងពិភាក្សា ការងារសំខាន់មួយ ។

ស្រស់ធីតាបញ្ជាក់វាចាម៉ឺងម៉ាត់ :

-រឿងពិភាក្សាការងារ ខ្ញុំពេញចិត្តណាស់ តែខ្ញុំមិនពេញចិត្តត្រង់ លោកពុំមែនប្រធានមេក្រុមនាគខ្មៅមែនទែននោះទេ ។

-អូបាទ ! គឺពិតដូចអ្នកនាងថាមែនតែខ្ញុំជាមេក្រុមរងដែលប្រធានធំ ប្រើមក ។

-លោកឈ្មោះ ប៉ាថាសិទ្ធ មែនទេ ? ខ្ញុំដឹងថា លោកជាអ្នកបាញ់កាំ ភ្លើងដៃត្រង់ លោកកសាងស្នាដៃបានឆាប់រហ័សណាស់ ។ ក្នុងរយៈពេលតែពីរ ឆ្នាំ លោកអាចឡើងឋានៈដល់ទៅប្រធានរង គឺពិតជាមិនធម្មតាមែន !

ព្រួស្រីខ្មែរម្នាក់ដ៏ទន់ភ្លន់ តែនិយាយម៉ឺងម៉ាត់ហើយចោះចំប្រវត្តិរបស់ ខ្លួនដូច្នេះ ធ្វើឱ្យបុរសញ្ញោចខ្លួនបារម្ភក្នុងចិត្តថា "នាងសេះញីនេះពិតជាចារនារី ដ៏ស្រួចស្រាវមែន" ។ ទឹករួចបុរសនោះហាក់ដូចជាអល់អែកក្នុងចិត្ត ។ ឆោម ឆើតបង្កើតវាចាថា :

-ណ្ហើយ! សុំលោកមានប្រសាសន៍មកចុះ តើលោកចង់ពិភាក្សារឿង អ្វី ?

-គឺរឿងក្បាលអ្នកតាសិរិទ្ធហ្នឹងណាំ !

តើវាយ៉ាងម៉េច ?

-ចៅហ្វាយខ្ញុំឱ្យខ្ញុំមកតថ្លៃជាមួយនាង គឺឱ្យនាង ១ លានដុល្លា ដើម្បី កុំឱ្យនាងលូកដៃចូលក្នុងរឿងនេះ ហើយនាងអាចបើកប្រាក់នៅប្រទេសណាក៏បាន ។

-លោកមើលងាយនារីខ្មែរពេកហើយ ! តាមពិតបុរសខ្មែរមួយចំនួន ជាជនពុករលួយមែន តែប្រវត្តិរបស់ចារជនខ្មែរពុំដែលពុករលួយឡើយហោង ... ។

នាងបង្អង់ឈប់សំដែងអាកប្បកិរិយាខឹងសំបារតាមផ្ទៃមុខ ធ្វើឱ្យមេក្រុមនាគខ្មៅប្រែប្រួលទឹកមុខដោយភ័យខ្លាច ។ នេះជាចិត្តសាស្ត្ររបស់ចារនារី នាងធ្វើជាខឹងដើម្បីវាស់ស្ទង់វិជ្ជាជាអាជីពនៃអ្នកបាញ់កាំភ្លើង ។ ឃើញថានាង មានប្រៀបជាងគេឆ្ងាយណាស់ ព្រោះនាងអាចធ្វើឱ្យគេញ្ញើចខ្លួន និងប្រែប្រួល ទឹកមុខដោយភ័យខ្លាច ។ ខ្លាចទីមួយគឺខ្លាចពេលទៅវិញចៅហ្វាយធំស្តីបន្ទោសថា ខ្លួនមិនកើតឱ្យមកចរចា គ្មានបានលទ្ធផល ។ ខ្លាចទីពីរ គឺខ្លួនដឹងថា នាងជាសិស្សសាលាចារកម្មទើបនឹងមកពីអាមេរិក ។ នាងជានារីម៉ឺងម៉ាត់ក្លៀវក្លាកាយវិការដូច រាជសីហ៍ភ្នែកដូចម្រិគ ។

មេក្រុមរងនាគខ្មៅ ធ្វើអេះអុញស្ទើរហើបវាចាមិនចេញ ។ ដើម្បីកុំឱ្យ ខាតពេលវេលា ស្រស់ស្រី នារីរដ្ឋ ពោលបញ្ជាក់ :

-ខ្ញុំសុំសួរលោកមួយម៉ាត់ ឥឡូវក្បាលអ្នកតាសីរិទ្ធនៅឯណា ?

មេក្រុមរងនាគខ្មៅឆ្លើយមិនដាច់ស្រេចក្នុងចិត្ត :

-បាទនែ ! ខ្ញុំមិនដឹងថា នៅឯណាទេ ?

ភ្លែត ! កាំភ្លើងភ្ជង់មេក្រុមរងនាគខ្មៅ ។ សហការីវាពីរនាក់ ភ័យ ស្លន់ធ្វើមុខមឹងមាំង បបូរមាត់ឡើងពណ៌ស្វាយ ។

ស្រស់ធីតាវាចាសង្កត់ធ្ងន់ៗ :

-នរណាហ៊ានដកកាំភ្លើង អ្នកនោះត្រូវស្លាប់មុនគេ ។

ពោលស្ទើរពុំទាន់ចប់ផង ស្រាប់តែផាំង ! នារីអ្នកបំរើម្នាក់ដែលកាន់ ថាសប៊ីយែរចូលមកត្រូវនារីរដ្ឋបាញ់សម្លាប់ ព្រោះនៅក្រោមថាស ដែលនាងកាន់នោះ មានកាំភ្លើងមួយដើមបំរុងធ្វើសកម្មភាព ។ នាងអ្នកបំរើដែលស្លាប់នេះ គឺជាភ្នាក់ងារលាក់ខ្លួនរបស់ក្រុមនាគខ្មៅ ។ ឆ្លៀតឱកាសរហ័សដូចរន្ទះនេះ មេក្រុមរងនាគខ្មៅក៏មិនអន់ដែរ វាបាញ់នារីរដ្ឋផាំង ! រួចហើយលាន់ផាំង ! មួយទៀត ។ មួយគ្រាប់ចុងក្រោយនេះគឺជាគ្រាប់របស់ នារីរដ្ឋ ធ្វើឱ្យវារបួសស្មាស្តាំដែលជាដៃកាន់កាំភ្លើង ។ វាចុករមួលរួចហើយវាឈរត្រង់ខ្លួនដូរកាំភ្លើង មកដៃឆ្វេងភ្ជង់ នារីរដ្ឋ ។ នារីរដ្ឋ ឈរត្រង់ខ្លួនភ្ជង់តបវិញ :

-ហាស់ ! ហាស់ ! ដល់ថ្នាក់នេះហើយលោកនៅហ៊ានលេងចិត្ត សាស្ត្រជាមួយខ្ញុំទៀត ?

ពោលពុំទាន់ចប់ មេក្រុមរងនាគខ្មៅធ្វើមាត់ស្ញេញ ដោយរបួសវាឈឺ ខ្លាំងពេកទ្រាំពុំបាន ។ ឆាកប្រយុទ្ធមួយប្រាវក៏បានកើតឡើងដោយសហការីវា ពីរនាក់បាញ់ស្រោចមកលើ នារីរដ្ឋ ។ តែមួយប៉ព្រិចភ្នែកប៉ុណ្ណោះ គ្នាវាពីរនាក់ក៏ក្ស័យប្រាណ ។ នារីរដ្ឋ សួរទៅនាយមេកងរង :

-ម៉េច ? លោកប្រាប់ ឬមិនប្រាប់ !

-បាទ ! ខ្ញុំអត់ដឹងមែន !

-ឈ្លើយ ខ្ញុំអាណិតលោក ខ្ញុំទុកជីវិតឱ្យលោកចុះ ។

ផាំង ! នារីរដ្ឋ បាញ់ដៃឆ្វេងរបស់វាទៀតធ្វើឱ្យវាចុករមួលប្រកាច់លើ ឥដ្ឋ ។ ភ្លាមនោះប្រាវ ! សំណាញ់ដែកធ្លាក់ពីលើពិដានដែលគេឆ្នៃទុកមកគ្រប ដណ្តប់លើចារនារីខ្មែរ ។ ទ្វារបើកខ្ទាក ! បុរសថៃពីរនាក់ចូលមកដល់បាញ់សំរុក ទៅលើនារីរដ្ឋ ។

ប៉ុង! ប៉ុង! ពួកវាទាំងពីរដួលខ្ពោក! ខ្ពោក! ។ ទោះជានៅក្នុងសំណាញ់ ក៏នាងអាចបាញ់បានដែរ តែស្រស់ធីតាមិនទាន់ហ៊ានវែកសំណាញ់រកច្រកចេញទេ ព្រោះខ្លាចវាចូលមកទៀត ។ ភ្លាមនោះសំឡេងមួយលាន់ឡើង "ប៉េឡាប៉ៃឡៃ !" ។ ឮដូច្នេះ នារីរដ្ឋ ក៏ពោលឡើងថា:

-ចូលមកចុះ !

នេះជាពាក្យគន្លឹះរបស់ភ្នាក់ងារសម្ងាត់ខ្មែរ ។ នាយត្រូវឱ្យសញ្ញា ទើបហ៊ានចូលខ្លាចក្រែងនាង នារីរដ្ឋ យល់ថា ជាក្រុមនាគខ្មៅ អាចបណ្ដាលឱ្យ នាយធ្វើដំណើរទៅឋាននរក ។ ចូលដល់ភ្លាមបុរសដាក់គន្លឹះទ្វារភ្លែត ទើបចូលទៅជួយលើកសំណាញ់ឱ្យនារីរដ្ឋ ចេញ ។ ស្រាប់តែ ប៉ុង ! ប៉ុង ! គ្រាប់កាំភ្លើងបាញ់ទ្វារបន្ទប់ ។ ស្នូរទម្ងន់ជើងធាក់ក្ដាំង ! ក្ដាំង ! នារីរដ្ឋ មើលមុខបហសការីដោយឆ្ងល់ ។ អ្នកកម្លោះម្ចីម្នាអូសដៃនារីរដ្ឋ ចូលក្នុងបន្ទប់ដាក់គន្លឹះគ្រឹប ! ស្រាប់តែ ក្ដាំង ! ផ្ទាំងទ្វារបន្ទប់ ឯណោះរលំគ្រេង ។ សហការីនារីរដ្ឋ ពោល ដោយញញឹម :

-មិនអីទេចៅហ្វាយ ! យើងចុះតាមច្រកនេះភ្លាមឡើង។

ពោលបណ្ដើរ អ្នកកម្លោះចុចគន្លឹះសម្ងាត់បណ្ដើរ ។ ឥដ្ឋការ៉ូបួនផ្ទាំង ស្រុតចុះឃើញមានជណ្ដើរមួយចុះទៅក្រោម ។ លុះចុះដល់ក្រោមឥតការ៉ូបិទ ជិតវិញ ។ សហការីដកចេញពីហោប៉ៅនូវកូនគ្រាប់បែកមួយ ប៉ុនផ្លែពុទ្រាធំ ដោយពោលថា :

-ពួកវានឹងចុះមកតាមនេះមិនខាន ! យើងត្រូវប្រើអានេះដើម្បី កំចាត់វាផង ដើម្បីបង្អាក់ដំណើរវាផង !

បង្កៃគ្រាប់បែករួច សហការីនាំចៅហ្វាយរត់ចេញទៅយ៉ាយលឿន ។ គេរត់តាមរូងក្រោមដីរួចទៅឡើងនៅគល់ស្វាយមួយធំ ដែលមានគុម្ពោតព្រៃ និងស្មៅបារាំងខ្ពស់ៗ ។

ប៉ាប់ ! ប៉ាប់ ! ប្រាវ ! ប្រាវ ! សំឡេងកាំភ្លើងតូចធំបាញ់ស្រោចមក លើស្មៅនិងគុម្ពោតព្រៃ ដើម្បីប្រហារចារនារីខ្មែរ និងសហការី ។ ឱ្យតែកន្លែងណាមានស្មៅរង្គើ កន្លែងនោះស្មៅត្រូវខ្ទេចអស់។ ពួកនាគខ្មៅបាញ់បណ្ដើរ បង្ខិតទីកាន់តែរួមតូចបណ្ដើរ ដើម្បីចាប់ខ្លួននារីរដ្ឋ និងសហការី ។

ចំណែកនៅឯផ្លូវថ្នល់ឯណោះវិញ ក្រុមនាគខ្មៅបីនាក់ កំពុងគ្រាហ៍ចៅហ្វាយវាដែលរបួសដៃទាំងសងខាងនោះចូលទៅក្នុងឡាន ។ ឡាននេះហៀប ចេញដំណើរស្រាប់តែឡានប៉ូលិសថៃមកទាន់កាន់កាំភ្លើងវែងភ្ជង់ពួកនេះ រឺខ្នោះជាប់ទាំងបួននាក់ ។ រួចហើយប៉ូលិសថៃជាងដប់នាក់ក៏ទៅព័ទ្ធចាប់ពួកនាគ ខ្មៅដែលកំពុងរុករក នារីរដ្ឋ និងសហការី ។ ពួកនាគខ្មៅទាំងនេះត្រូវប៉ូលិស ថៃ រឺខ្នោះទាំងអស់ ។

នារីរដ្ឋ ថ្លែងអំណរគុណចំពោះប៉ូលិសថៃយ៉ាងស្រស់ស្រាយ ។ ប្រធាន ក្រុមប៉ូលិសថៃម្នាក់ ដែលមានភ្នែកភ្លឺថ្លាជាព្រាននារីញញឹមបិទមាត់ជិត សាសងជាមួយ នារីរដ្ឋ ឥតឈប់ ។ ទៅដល់ការិយាល័យ ប៉ូលិសថៃ លោកប្រធានក្រុម ដែលមានឋានៈស្នងការបានអញ្ជើញ នាងចូលទៅក្នុងបន្ទប់ពិសេសរបស់លោក ដើម្បីពិភាក្សាការងារជាបន្ត ។

លោកផ្ដើមវាចាថា :

-ជាបឋម ខ្ញុំសូមសរសើរដោយស្មោះចំពោះវីរភាពរបស់នាងកូនចៅ ខ្ញុំបានលើកសរសើរនាងជាប់ជានិច្ច ហើយព្រមជាមួយនេះ ខ្ញុំក៏មានសរសើរ ចំពោះសហការីរបស់នាងដែរ ពោលគឺពុំដឹងគេប្រើវិធីណា ទើបគេអាចស្គាល់ថាភោជនីយដ្ឋាន ខារ៉ងរិទ្ធ ជាភោជនីយដ្ឋានរបស់ក្រុមនាគខ្មៅ ។ ខ្ញុំទើបនឹងបាន ពតិមាននេះពីម្សិលមិញដោយសារភ្នាក់ងារសម្ងាត់របស់នាងរាយការណ៍... ។

បង្អង់បន្តិច លោកស្នងការមានប្រសាសន៍បន្ត :

-ពួកនាគខ្មៅព័ទ្ធចាប់នាងដល់ថ្នាក់នេះ ម៉េចក៏នាងនៅតែអាចរត់រួច ?

គិតបន្តិចទើប នារីរដ្ឋឆ្លើយ :

-គឺសហការីខ្ញុំ នាំរត់តាមរូងក្រោមភោជនីយដ្ឋាន ។

-គិតទៅគួរឱ្យសរសើពួកនាងមែន !

-ខ្ញុំសូមអរគុណលោកច្រើនណាស់ ដែលលោកចេះសរសើរពួកខ្ញុំ ។ តែណ្ហើយ ! យើងគិតពិភាក្សាការងាររបស់យើងទៀត ។

លោកស្នងការដែលមានអារម្មណ៍ និងកែវភ្នែកភ្លូកភ្លឹកទៅលើ សម្ផស្សល្អឥតពីររបស់ នារីរដ្ឋ លុះឮដូច្នេះក៏ហាក់អៀនពោលថា :

-ឥឡូវនេះ មេក្រុមរងនាគខ្មៅត្រូវប៉ូលិសយើងចាប់បានហើយ តើ នាងមានបំណងអ្វីដែរ ?

ស្រស់ស្រីឆ្លើយបញ្ជាក់ :

-ចាំ ! ខ្ញុំចង់បានពត៌មានពីទីតាំងធំរបស់នាគខ្មៅ ដើម្បីស៊ើបរកក្បាលអ្នកតាសិរិទ្ធថា តើនៅក្នុងក្រុមរបស់វា ឬវាលក់បាត់ទៅហើយ

-ដើម្បីឱ្យការសហការរវាងប្រទេសទាំងពីរបានជិតស្និទ្ធស្មោះត្រង់ និងកក់ក្ដៅ ខ្ញុំសូមអញ្ជើញនាងចូលរួមសួរ ចម្លើយមេក្រុមរងរបស់វា ។

បង្អង់ចិត្ត លោកស្នងការពោលបន្ត :

-សព្វថ្ងៃនេះការសួរចម្លើយមិនពិបាកទេ ព្រោះយើងប្រើប្រព័ន្ធកុំព្យូ ទ័រទំនើប ។

បន្ទាប់មកលោកស្នងការ និងនារីរដ្ឋ ចូលទៅក្នុងបន្ទប់សួរចម្លើយ ។ នៅទីនេះគេដាក់មេក្រុមរងរបស់ក្រុមនាគខ្មៅ ដែលទើបនឹងរុំរបួសទាំងសង្ខាងរួចឱ្យដេកលើគ្រែដោយចងដៃ ចងជើងវាជាប់នឹងគ្រែ ដើម្បីកុំឱ្យវារើបម្រះ ។ រួចគេបើកកុំព្យូទ័រមួយដែលមានកាស ដូចកាសស្ដាប់កូនម៉ាញ៉េយកមកពាក់នៅត្រង់សៀតផ្កាទាំងសងខាងរបស់វា ។ បន្ទាប់មកគេសួរវា ហើយចម្លើយទាំងអស់លេចឡើងជាអក្សរនៅក្នុងកុំព្យូទ័រ រួចគេព្រីនមកលើក្រដាសដូចជាព្រីន ចេញពីកុំព្យូទ័រធម្មតា ។

ឥឡូវយើងបានស្គាល់ឈ្មោះមេធំរបស់វា ស្គាល់ទីតាំងរបស់វា និងដឹង ថាក្បាលអ្នកតាសិរិទ្ធ កំពុងស្ថិតនៅក្នុងក្រុមនាគខ្មៅនៅឡើយ កញ្ញា នារីរដ្ឋ ក៏ថ្លែងអំណរគុណជាថ្មីម្ដងទៀត ចំពោះលោកស្នងការ និងយល់ព្រមតាមផែន ការរបស់លោកស្នងការដែលនឹងត្រូវទៅឡោមព័ទ្ធ ចាប់ក្រុមនាគខ្មៅនៅក្នុងថ្ងៃអាទិត្យខានស្អែកនេះ ។

## ជំពូក៧
## ប្រធាននាគខ្មៅបាត់ខ្លួន

ថ្ងៃនេះជាថ្ងៃសុក្រ ស្អែកគឺជាថ្ងៃសៅរ៍ ខានស្អែកគឺជា ថ្ងៃអាទិត្យ ។ បីថ្ងៃគឺជាថ្ងៃ ដ៏សែនយូរអង្វែងសំរាប់សហការីរបស់ នារីរដ្ឋ០៧១ ប៉ុន្តែផ្ទុយមកវិញបីថ្ងៃសំរាប់ នារីរដ្ឋ ហាក់ដូចជាបីម៉ោងទៅវិញទេ ព្រោះ នារីរដ្ឋ បានប្រើវិធីសមាធិ នៅពេលដែលនាងគិតដល់ក្បាលអ្នកតាសិរិទ្ធ ។ នារីរដ្ឋ គិតថា អ្វីៗទាំងអស់សុទ្ធតែសត្យានុម័តជាអ្នកបញ្ជាទោះបីលទ្ធផលបានមកដោយសារអត្តនោម័តជាអ្នកសំរេចក៏ដោយ ។ តាមក្រិតក្រមចិត្តវិជ្ជាដែល នារីរដ្ឋ បានរៀន : សមាធិ គឺជាវិធីមួយដ៏ល្អប្រសើរសំរាប់តម្រង់ចិត្តយើងឱ្យដើរតាម ផែនការដែលបានគ្រោងទុក ព្រោះវាជាវិធីធ្វើឱ្យចិត្តយើងបរិសុទ្ធភ្លឺថ្លា ប្រកបដោយសុភវិនិច្ឆ័យចំពោះបញ្ហាដែលវាបំរុងនឹងកើតឡើង ។ ក្នុងរយៈពេលបីថ្ងៃ នេះប៉ូលិសថៃសហការី និងខ្លួននាងផ្ទាល់ សុទ្ធតែបានត្រៀមលក្ខណៈគ្រប់បែបយ៉ាងទាំងអស់ ។ ដូច្នេះទោះបីថ្ងៃណាក្រុមនាគខ្មៅធ្វើអ្វី ក៏ប៉ូលិសថៃដឹងទាំងអស់ ។ សំណួរមួយអាចចោទថា : "ហេតុអ្វីបានជាប៉ូលិសថៃមិនក្របួចពួកនាគ ខ្មៅនៅថ្ងៃនេះតែម្ដងទៅ ?..." ។ នេះគឺជារឿងរបស់ការងារចារកម្ម ពោលគឺ កាលណាគេ ចាប់បានមេក្រុមរងរបស់នាគខ្មៅហើយ វាប្រាកដជាអាចបំបែកសំបុក ដូចសំបុកឃ្មុំត្រូវភ្លើងពុំខាន ។ ដូច្នេះគេនឹងអាចរកឃើញមេឃ្មុំ ។

ប៉ុន្តែចំពោះនាគខ្មៅវាពុំដូចនេះទេ ថ្ងៃសុក្រកន្លងផុត ថ្ងៃសៅរ៍ កន្លងផុត ប៉ូលិសថៃពុំឃើញមានឃ្មុំមួយណាហើរចេញពីសំបុក ឬហើរចូលសំបុកសោះ ។ ហេតុការណ៍នេះបង្ហាញថា ក្រុមនាគខ្មៅជាក្រុមដ៏មានចំណាស់ខាងបទពិសោធន៍ ។ នៅឯភូមិគ្រឹះរបស់ក្រុមនាគខ្មៅ គេសង្កេតឃើញតែអ្នកដាំស្ល ពីរនាក់ ចេញទៅផ្សារទិញម្ហូបរួចចូលមកវិញតែប៉ុណ្ណោះ ។

ប៉ូលិសថៃ បានតាមដានអ្នកទិញម្ហូបគ្រប់ជំហានទាំងអស់ ។ ថ្ងៃសុក្រ គេទិញអ្វីខ្លះ ទិញអស់ប្រាក់ប៉ុន្មាន ថ្ងៃអាទិត្យទិញអ្វីខ្លះ ទិញអស់ប្រាក់ប៉ុន្មាន គេសុទ្ធតែដឹងទាំងអស់ ។ អ្នកទិញម្ហូបទាំងពីរនាក់ផឹកទឹកក្រូចនៅកន្លែងណា និយាយជាមួយអ្នកលក់ថាម៉េចខ្លះ ប៉ូលិសថៃសុទ្ធតែដឹង សុទ្ធតែឮទាំងអស់ ព្រោះគេបណ្ដាក់គ្នាដូចខ្សែដើម្បីតាមដាន ។ តែទីបំផុតគឺគ្មានពតិមានអ្វីប្លែកឡើយ ។ ថ្ងៃនេះពេញមួយថ្ងៃ

ថ្ងៃអាទិត្យបានកន្លងផុតទៅទៀត... លទ្ធផល ស្ងាត់ឈឹង។ រាត្រីកាលឈានដល់ម៉ោង៧យប់ គេឃើញឡានម៉ែសឺដេសមួយគ្រឿងជិះដោយបុរសពីរនាក់ធ្វើដំណើរទៅក្លឹបកំសាន្តដ៏ធំមួយនៅកណ្តាលក្រុងបាងកកក្រោមផ្លាកថា : "រាត្រីទឹកឃ្មុំ" ។ នៅទីនេះប៉ូលិសបានតាមដានអ្នកទាំងពីរគ្រប់ជំហានទាំងអស់ ពោលគឺអ្នកទាំងពីរបានចូលទៅចាក់ល្បែងម្នាក់ ចាញ់អស់ពីរម៉ឺនបាត-ម្នាក់ចាញ់អស់ជាងប្រាំម៉ឺនបាត រួចហើយគេក៏នាំគ្នាចូលទៅក្នុងបន្ទប់ "ដោះកូយ" នាំស្រីស្នេហ៍ម្នាក់មួយឡើងទៅលេងស្ថានសួគ៌ ។ ក្រុមប៉ូលិសសម្ងាត់ថៃជិតដប់នាក់តាមដានបុរសក្រុមនាគខ្មៅ-គឺស្អិតមែនមិនធម្មតាទេ ។ នៅខាងក្រៅក្លឹបកំសាន្តប៉ូលិសសម្ងាត់បួននាក់យាមឡានម៉ែសឺ ដេសមួយ ។

នៅឯស្នងការដ្ឋាន បុរសក្រុមនាគខ្មៅទាំងពីរបានត្រូវប៉ូលិសដាក់ខ្នោះជាប់នឹងគ្រែ ។ កុំព្យូទ័រសួរចម្លើយក៏បានសួរអ្នកទាំងពីរ ។

ប៉ៃ លិតគួថគោញី ! ចម្លើយដែលថតចេញនៅលើក្រដាសគឺអ្នកទាំងពីរគេប្រើមក ។ បុរសទាំងពីរដែលនាំស្រីស្នេហ៍ម្នាក់មួយ ឡើងស្ថានសួគ៌នោះ គឺជាប្តីប្រពន្ធរបស់មេក្រុមនាគខ្មៅ ។ ប្រពន្ធរបស់មេក្រុមនាគខ្មៅ ក្លែងខ្លួនជាបុរសរួចឡើងឡានម៉ែសឺដេសទៅចាក់ល្បែងនៅក្លឹបកំសាន្ត រួចហើយទៅលេងស្រីនៅក្នុង "បន្ទប់ដោះកូយ" ។ គឺនៅក្នុងបន្ទប់នេះ ហើយដែលគេប្តូរឱ្យកូនចៅ របស់គេបើកឡានម៉ែសឺដេសវិលមកភូមិគ្រឹះវិញ ។ ហើយអ្វី១តទៅនោះ អ្នកជាប់ខ្នោះនៅលើគ្រែទាំងពីរនាក់នេះនៅពុំបានដឹងអ្វីទេ ។

នៅទីបំផុតក្រុមប៉ូលិសថៃអស់ពីឈឺចិត្ត ចាញ់បោកពួកក្រុមនាគខ្មៅ បែរជាសើចស្ទើរភាគនោមទៅវិញ ។

លោកស្នងការទូរស័ព្ទទៅកាន់លោកអគ្គនាយកក្រសួងមហាផ្ទៃទាំង ភ័យខ្លាច :

-បាទ !... បាទ !... តេជគុណ ! ប្តីប្រពន្ធមេក្រុមនាគខ្មៅ គេចខ្លួន បាត់ទៅហើយ ! ឥឡូវតើយើងឡោមព័ទ្ធចាប់ពួកវា តាមផែនការឬទេតេជគុណ ?

លោកអគ្គនាយកតបមកវិញ :

-ត្រូវតែធ្វើតាមផែនការរបស់យើងក្របួចចាប់ពួកវាឱ្យអស់កុំឱ្យសល់ ម្នាក់ បើអាចជៀសបានគឺកុំធ្វើឱ្យពួកវាស្លាប់ម្នាក់ឱ្យសោះ ។

លោកស្នងការពោលគោរព :

-ទទួលបញ្ជា !

លោកស្នងការពោលចប់ ស្រាប់តែទូរស័ព្ទលោកអគ្គនាយកឱ្យសញ្ញា :

-សូមគោរពលោកអគ្គនាយក ! នាងខ្ញុំ នារីរដ្ឋ ០៧១ សូមលោកអគ្គនាយកបញ្ជាឱ្យរំនែកឆេរច្រកព្រំដែនថៃ ម៉ាឡេស៊ី ជាបន្ទាន់ ព្រោះប្តីប្រពន្ធមេក្រុមនាគខ្មៅ ធ្វើដំណើរទៅព្រំដែនហើយ ! ។

លោកអគ្គនាយកតប :

-បាទអរគុណច្រើននាង !

ស្រស់ស្រីបោះសំដីយ៉ាងទន់ផ្អែមតាមទូរស័ព្ទ :

-ខបចៃឡាយឡាយ ! អរគុណច្រើន

លោកអគ្គនាយកសំដែងទឹកមុខមាំពិចារណាថា : "ហ៊ឺ ! ពួកក្រុម នាគខ្មៅ ពូកែមែន ! វាធ្វើឱ្យយើងឈឺក្បាលមែនទែន" ។

ចំណែកលោកស្នងការ នាំប៉ូលិសកន្លះរយដែលមានឡានមេក្រូទៅជាមួយផង ។ នៅមុខភូមិគ្រឹះនាគខ្មៅ លោកស្នងការស្រែកដោយខ្លួនឯងថា :

-អាឡូ ! អាឡូ ! អ្នកនៅក្នុងភូមិគ្រឹះទាំងអស់សូមអញ្ជើញមកបង្ហាញខ្លួនចំពោះមុខប៉ូលិស ប្តីប្រពន្ធមេក្រុមនាគខ្មៅត្រូវប៉ូលិសចាប់ខ្លួនបាន ហើយ ! អ្នកនៅខាងក្នុងសូមបើកទ្វារជាប្រញាប់ !

សម្លេកស្រែកឡើង ៤-៥ដង នៅតែស្ងាត់ឈឹង គ្មាននរណាចេញមកបើកទ្វាររបងសោះ ។ លោកស្នងការយកសោរមកចាក់សាកបើកទ្វាររបងដោយខ្លួនឯង រួចហើយលោកបញ្ជាឱ្យក្រុមប៉ូលិសដែលមានឆ្កែចេះហិតក្លិនគ្រាប់មីន លែងឱ្យវារត់ពាសពេញទីធ្លាជុំវិញភូមិគ្រឹះ ដើម្បីការពារក្រែងក្រុមនាគខ្មៅបង្កប់គ្រាប់បែក។ បន្ទាប់មកលោកស្នងការបញ្ជាឱ្យគេបញ្ជាំងហ្វាឡានបីគ្រឿង ដើម្បីបំភ្លឺភូមិគ្រឹះ។ ឯសម្លេង

មេក្រូនៅតែស្រែករន្ទើនឱ្យគេបើកទ្វារគេហដ្ឋាន ។ បន្ទាប់មកទើបមានស្រីពីរនាក់ ដែលជាអ្នកដាំស្ល និងមានបុរសពីរនាក់ ចេញមកបង្ហាញខ្លួនចំពោះប៉ូលិស។ ប៉ូលិសបានជំរាបអ្នកទាំង៤ តាមដំណើររឿង និងអញ្ជើញអ្នកទាំង៤ ឡើងឡានទៅមន្ទីរស្នងការ ដើម្បីសួរចម្លើយ ។ ប៉ូលិសមួយក្រុមបានរុករើគ្រប់បន្ទប់ទាំងអស់នៅក្នុងភូមិគ្រឹះនេះ ។ គេរកឃើញអាវុធវែង៦ដើម និងអាវុធខ្លីពីរដើម ព្រមទាំងគ្រាប់បែកម្តៃគ្រាប់ផង ។ លោកស្នងការបានបញ្ជាឱ្យប៉ូលិស៦នាក់ និងឆ្កែប្អូនក្បាលនៅយាមភូមិគ្រឹះនេះ ។

ម៉ោង ៤ទៀបភ្លឺ ទើបលោកស្នងការចូលដល់មន្ទីរស្នងការវិញ ។ ប៉ូលិសម្នាក់ៗខឹងក្នុងចិត្តយ៉ាងខ្លាំង : "ហ៊ឺ ! ពួកក្រុមនាគខ្មៅអស្ចារ្យមែន ធ្វើឱ្យឯងអត់ងងុយមួយយប់ទទេ !" ។

នៅមន្ទីរស្នងការប៉ូលិស ពួកក្រុមនាគខ្មៅទាំងបួនបានត្រូវប៉ូលិសដាក់ កុំព្យូទ័រសួរចម្លើយគ្មានបានលទ្ធផលអ្វីឡើយ ។ ម្នាក់ៗសុទ្ធតែឆ្លើយថាពុំដឹង ចៅហ្វាយស្រី ចៅហ្វាយប្រុសរបស់ខ្លួនទៅណាទេ ។

នៅឯព្រំដែនថៃ-ម៉ាឡេ ការឆែកឆេររកមេក្រុមនាគខ្មៅ និងក្បាល អ្នកតាសិរិទ្ធបានប្រព្រឹត្តទៅតាំពីម៉ោង១២យប់ រហូតដល់ម៉ោង១២ថ្ងៃត្រង់ នៅតែគ្មានបានលទ្ធផលអ្វីឡើយ ។ តែការឆែកឆេរនៅតែប្រព្រឹត្តទៅយ៉ាងមធ្យ័តជានិច្ច ។

មនុស្សគឺអញ្ចឹង ! ព្រំដែនខ្មែរ-ថៃគឺអញ្ចឹង ! ព្រំដែនថៃ-ម៉ាឡេ គឺអញ្ចឹង ! មនុស្សល្អពុំអាចចេញចូលបានឡើយ តែបើមនុស្សអាក្រក់ គឺចេញចូល ម៉ាស្រណុក ! មិនថាអញ្ចឹង ! អស់ទាស់តែម្តង ។

នៅទីមនឹងពេល ដែលគេដាក់កុំព្យូទ័រសួរចម្លើយក្រុមនាគខ្មៅ ទាំងបួននាក់ នារីរដ្ឋ០៧១ និងក-៥៣ បានសុំអនុញ្ញាតពីលោក ស្នងការត្រួតពិនិត្យ ឡានមែរសឺដេសរបស់ក្រុមនាគខ្មៅ ដែលបាននាំយកទៅកាន់ ស្នងការដ្ឋាននោះ ។ នារីរដ្ឋ០៧១ និងក-៥៣ ឆែកឆេរក្នុងឡាន-ក្រោម ពូកឡានក្នុងពូកឡាន និងក្នុងគូទឡានរួច នារីរដ្ឋ សួរទៅសហការីថា :

-ម៉េចទៅ ? បង ក-៥៣ ឯងមានឃើញអ្វីប្លែកទេ ?

ក-៥៣ គិតដោយអេះអុញមួយសន្ទុះ ទើបឆ្លើយថា :

-បាទ ! អត់ឃើញអ្វីប្លែកទេ !

នារីរដ្ឋ ហៅ ក-៥៣ ឱ្យទៅមើលគូទឡានម្តងទៀត ដោយឱ្យ ក-៥៣ បើកទ្រនាប់ក្រាលគូថឡានចេញរួចឱ្យ ក-៥៣ ពិនិត្យសារជាថ្មីម្តងទៀត ។ ពិនិត្យរួចទើប ក-៥៣ ភ្ញាក់ថា :

-អូហូ ! គូទឡាននេះមានស្នាមរង្វង់មូលធំមួយប្រហែលគេធ្វើសំរាប់ធ្វើអ្វីហើយ !

នារីរដ្ឋ បញ្ជាក់ថា :

-ប្រាកដណាស់ សូមបងត្រួតពិនិត្យពីខាងក្រោមគូទឡានឱ្យច្បាស់មើល ដើម្បីទុកជាបទពិសោធន៍ ។

មែន ! ខួរក្បាលមនុស្សធម្មតា និងខួរក្បាលរបស់ចារនារីរូបនេះមិនដូចគ្នាទេ គឺខុសទាំងគំនិតប្រតិកម្មខុសទាំងបញ្ញាញាណ ។ នារីរដ្ឋឱ្យ ក-៥៣ ប្រើពិលដែលធ្វើភ្ជាប់ជាមួយប៊ិចយកទៅបញ្ចាំងមើលពីខាងក្រោមគូទឡាននៅពេល ក-៥៣ លូនចេញពីក្រោមគូថឡានមកវិញលោកបញ្ជាក់ថា :

-បាទ ! ដូចពាក្យចៅហ្វាយថាមែន គឺខ្ញុំរកឃើញខ្ចៅមួយសំរាប់មួលភ្ជាប់រង្វង់មូលនោះ ឯនៅម្ខាងរង្វង់មូល គឺមានត្រចៀកតូច មួយសំរាប់ប្រើក្នុងការបើកបិទ ។

នារីរដ្ឋ សន្និដ្ឋានថា :

-ប្រាកដណាស់ហើយ ! គឺនៅព្រមពេលដែលប្តីប្រពន្ធក្រុមនាគខ្មៅចូលទៅចាក់ល្បែង នៅខាងក្រៅក្លឹប សហការីរបស់នាគខ្មៅ បានលូនពីក្រោម ឡានវាឆ្លងមកក្រោមឡានមួយទៀត រួចទើបលូនមកក្រោមឡានមែរសឺដេស រំដោះយកក្បាលអ្នកតាសិរិទ្ធ តាមរង្វង់មូលនោះឯង ។ ព្រោះហេតុនេះទើប ប៉ូលិសសម្ងាត់ថៃបួននាក់ ដែលយាមឡានមែរសឺដេស មួយពុំដឹងអ្វីសោះនោះ ។

សហការី ក-៥៣ មើលមុខចៅហ្វាយស្រីដោយក្តីគោរព កោត សរសើរនិងសួរថា :

-ឥឡូវ តើចៅហ្វាយឱ្យខ្ញុំបាទធ្វើអ្វីទៀត ?

-អ្វី១ គឺចប់អស់ហើយ យើងអាចបែកគ្នាបាន យើងត្រូវបែកគ្នាមួយរយៈ តែថ្ងៃស្អែកសូមបងអញ្ជើញទៅជួបឯកឧត្តម ឯកអគ្គរាជទូតរបស់យើងកុំខាន ។ សូមព្រលឹងអតីតព្រះមហាក្សត្រខ្មែរជួយទ្រទ្រង់ជីវិតបងជារៀងរហូត ! ព្រោះយើងទៅជួបគ្នា នៅម៉ាឡេទៀត ! ។

-ខ្ញុំបាទក៏អញ្ចឹងដែរ ខ្ញុំសូមឧទ្ទិសចំពោះវិញ្ញាណក្ខ័ន្ធនៃព្រះបាទ ជ័យ វរ័្មនទី២ ដែលឱ្យគេកសាងក្បាលអ្នកតាសិរិទ្ធនេះ សូមព្រះអង្គជួយថែរក្សាចៅ ហ្វាយឱ្យបានសេចក្តីសុខជានិច្ចនិរន្តរ៍ ! ។

## ជំពូកទី៨
## ចូលសំបុកនាគខ្មៅ

នារីរដ្ឋ ០៧១ អង្គុយម្នាក់ឯងក្នុងទីកមុខម៉ឺងម៉ាត់ កំពុងអានកាសែត ម៉ាឡេស៊ី ជាភាសាអង់គ្លេសនៅក្នុងភោជនីយដ្ឋានមួយ ។ ម៉ោងជាងប្រាំពីរ ហើយស្រស់ស្រីពុំទាន់ឃ្លានអាហារទេ ។ អង្គុយជិតមួយម៉ោង នាងញ៉ាំក្រូចច្របាច់អស់មួយកែវ ដើម្បីកែអផ្សុក នាងហៅថែមមួយកែវទៀត ។ ឥឡូវខ្វះ ដប់នាទីត្រូវជាពីរម៉ោងហើយ...

ក្នុងរយៈពេលនេះស្រស់ស្រីធីតាឃើញការចម្លែកមួយនៅនឹងអ្នកលក់កាសែតឱ្យនាងតែម្តង ។ នរៈនេះ ជាជនជាតិម៉ាឡេ មានរាងធាត់មាំតែកាយវិការរហ័សរហួន ។ នាយប៉ិនរាក់ទាក់ភ្ញៀវប៉ិននិយាយបញ្ចុះបញ្ចូលភ្ញៀវណាស់ ។ ក្នុងពេលជិតពីរម៉ោងនេះនាយលក់បានកាសែតប្រាំពីរសន្លឹក ។ អ្វី ដែលនារីរដ្ឋកត់សំគាល់បាននោះ គឺភ្ញៀវបួននាក់ ដែលទិញកាសែតនាយ សុទ្ធ តែបាននិយាយតិច១មកកាន់នាយ ហើយនាយនិយាយតបវិញហាក់ដូចជាគោរពណាស់ ។ នេះជាចំនុចខ្សោយរបស់អ្នកលក់កាសែតដែលនារីរដ្ឋចាប់អារម្មណ៍។ ជាងនេះទៅទៀតឃើញថា អ្នកទិញកាសែតទាំងបួននាក់មកពេលព្រម១គ្នា តែដើរដោយឡែក១ពីគ្នា ។ ពីរនាក់ជិះម៉ូតូធុនធំពីរនាក់ជិះឡាន ។ អ្វីដែលលំអិតជាងនេះទៅទៀតនោះ គឺខ្សែក្រវែករបស់អ្នកទាំងបួនតែងលួចមើលមកស្រស់ធីតា ។ កញ្ញា ឆើត០៧១ ឱ្យគេគិតលុយរួចក៏ងើបចេញស្រាប់តែរអិលជើងទៅប៉ះអ្នកទិញកាសែតម្នាក់ ធ្វើឱ្យនាងភ្លាត់មាត់ជាភាសាអង់គ្លេសដោយស្វ័យប្រវត្តិ:

-សុំទោសលោក !...

នាងពោលបណ្តើរញញឹមដាក់ភ្ញៀវបណ្តើរ ។ ភ្ញៀវក៏ញញឹមតបវិញ ។ មាណវី គិតក្នុងចិត្តថា "អីយ៉ា ! មិនស្រួលទេអាគាត់នេះមានអាវុធខ្លីនៅក្រោម ខ្សែក" ។ ភ្លាមនោះម្នាក់ទៀតដែលទិញកាសែតដែរនោះ ដើរមកប៉ះនាងស្រាប់តែនាងស្រែកថា :

-ចោរ ! ចោរ !

អ្នកប៉ះនាងឈរធ្មឹងធ្វើពើក្នុងទឹកមុខឡិងឡង់ថា ខ្លួនគ្មានលួចអ្វីរបស់នាងទេ ។ នារីរដ្ឋ ក៏ហក់បីជំហានទៅក្របួច-ក អ្នកទិញកាសែត ម្នាក់ផ្សេង ទៀតដែលកំពុងដើរចេញជិតដល់មាត់ទ្វារ ។ ស្រីស្រស់ទាញកាបូបពីហោប៉ៅ វាចេញមកបង្ហាញគេដោយប្រកាសថា :

-នេះជាកាបូបរបស់ខ្ញុំ វាទទួលពីបុរសម្នាក់នោះដែលបោះមកឱ្យវា ។

បុរសម្នាក់ដែលធ្វើពើក្នុងទឹកមុខឡិនឡង់ស្ទុះមកចង្អុលមុខនាង :

-នែនាងចង្រៃ មិនត្រូវចោទប្រកាន់គេតែផ្តេសផ្តាសអញ្ចឹងទេ ភស្តុ តាងនៅលើអ្នកណា គឺអ្នកហ្នឹងហើយ ។

បុរសដែលទទួលកាបូបនាងមកទុកក្នុងហោប៉ៅខោ ស្រែកដោយ ចង្អុលមុខនាងថា :

-នាងឯងជាចោរលួចកាបូបរបស់យើង ! មកលូកយកកាបូបពីហោ ប៉ៅយើង ស្រែកថាយើងជាចោរទៀត ។ ឆ្លៀតឱកាសនេះ បុរសដែលមានកាំភ្លើងខ្លីក្រោមខ្សៀកលើកជើងធាក់នាងប៊ិប ! នាងមិនដួលក៏ព្រលែងមួយដៃប៉ុង ! ហើយនាងបណ្ដោយឱ្យជំហាររបស់នាងវិលទៅមុខបង្វើរកែងផស ! រួចខ្លួន នាងវិលខ្វាល់ បង្វើរកែងថែមមួយផស ! ទៀត ធ្វើឱ្យគ្នាវាបីនាក់ត្រូវរបួស ។ អាអ្នកទិញកាសែតទីបួន ធ្វើមិនដឹង វាធ្វើមុខមឹងមាំង១ តែវាមិនអាចគេចការពិតនៅក្រោមក្រសែភ្នែករបស់នារីវដ្តបានឡើយ ។ ព្រោះនាងឃើញវាមានទឹកមុខមាំស្រស់ញញឹម ។ ស្រស់ស្រីដើរទៅកាន់វាដោយខ្វាក់វាចាទន់ផ្អែម :

-ម៉េចទៅបងប្រុស ! នៅធ្វើពើដល់ណា ? ឥឡូវតើបងចាប់ផ្ដើមមុន ឬខ្ញុំចាប់ផ្ដើមមុន ?

ពោលរួចស្រស់ធីតា ធ្វើជាដាល់មួយដៃសំដៅចំមុខវា វាគេចផុត គេចផុតស្រាប់តែ វ៉ិប! វ៉ិប ! ពីរជើងផ្ទួនស្រោចមកលើនាង។ កញ្ញាកំសត់ តម្លោះ វាចាថា :

-ហ៊ឺះ ! ខ្លាលាក់ក្រចក ឥឡូវលោកចាំទទួលណា៎ ! ពោលរួចស្រស់ស្រីព្រលែងពីរដៃផ្ទួននិងពីរជើងផ្ទួន តែបុរសនេះគេចផុតទាំងអស់។ វាសំដែងទឹកមុខបង្វើរពីរជើងផ្ទួនមកវិញ ។ ធីតាគេចផុតធ្វើជាខូចលំនឹងរាងរកដួល វាក៏បន្ថែមពីរជើងផ្ទួនទៀត ស្រស់ស្រីសងមួយដៃប៊ិប ! ចំក្បាលពោះវា ធ្វើឱ្យវាចុករមួល ។ នេះជាស្នៀតបញ្ឆោតឱ្យពស់ហក់មកចឹក រួចយកក្រមាមដៃខ្វេះប្រមាត់ពស់ ។ ភ្លាមនេះស្រាប់តែវ៉ប់ ! វ៉ប់ ! វិប ! វិប ! វ៉ប់ ! វ៉ប់ ! គ្នាវាបី នាក់វាយសំរុកផ្ទួនមកលើនាង ។ នាងគេចផុត ស្រែកថា :

-អញនឹងឱ្យឯងទាំងបីស្ថិតក្នុងករណីអាមួយនោះ !

ពោលរួចនាងប្រើស្នៀតបីជាបន្តបន្ទាប់គ្នា គឺស្នៀតហនុមានហោះ ។ ស្នៀតព្រះពាយចរ និងស្នៀតទេពធីតាលេងភ្លេង ធ្វើឱ្យពួកវាទាំងបីរបួសខុស១ គ្នា គឺអាមួយចំក្បាល អាមួយចំភ្នែក អាមួយធ្លាក់ធ្មេញពីមាត់ ។

នារីវដ្ត អូសក្បាលវាទាំងបួនមកផ្ដុំគ្នារួចសួរថា :

-ម៉េច ? ចង់សាកល្បងលេងកាំភ្លើងឬ ? នេះនែយកទៅ !

ពោលចប់ស្រស់ស្រីយកកាំភ្លើងបួនដើមពីក្នុងហោប៉ៅរបស់នាងមកបោះឱ្យវា ។ ស្រាប់តែពួកវាស្រឡាំងកាំងគ្រប់១គ្នា ។ វាគិតថាហេតុអ្វីបានជានាងរហ័សមើលតែខ្មោចព្រាយអញ្ចឹង ។ កាំភ្លើងរបស់ខ្លួនត្រូវនាងលួចយកទៅនៅតែខ្លួនពុំដឹងទៀត ។

ព្រមជាមួយនោះ ឡានប៉ូលិសម៉ាឡេក៏មកដល់ ព័ទ្ធចាប់ពួកវាទាំងបួននាក់ វ៉ៃខ្នោះដាក់ឡាននាំយកទៅ ។ នារីវដ្ត០៧១ បើកឡាននាងទៅតាម ប៉ូលិសម៉ាឡេដោយមានលោកស្នងការកំដរនាង សរសើរនាងពុំដាច់ពីមាត់ ។

លុះទៅដល់មន្ទីរស្នងការ លោកនាយកបញ្ជាឱ្យប៉ូលិសរៀបចំម៉ាស៊ីន កុំព្យូទ័រ ដើម្បីសួរចម្លើយ ។ នារីវដ្ត០៧១ ពោលដោយញញឹមថ្កាល់ខូចថា :

-មិនបាច់ទេលោកនាយក ខ្ញុំឱ្យវាសាកថ្នាំខ្មែរម្ដង ។

-ពោលរួច នាងយកកូនដបមួយចេញពីក្នុងហោប៉ៅមកបង្ហាញអា ចោរម្នាក់ :

-ម៉េចទៅ ! ម៉េចក៏បើកភ្នែកធំ១ម្ល៉េះ ? ឯងស្គាល់ថ្នាំខ្មែរនេះដែរ ...

អាចោរឆ្លើយតបវិញដោយភ័យខ្លាច :

-បាទ ! បាទ !... ខ្ញុំមិនបាច់ផឹកក៏បានដែរ នាងចង់សួរអីសួរមកចុះ...

-ហាស់ ! ហាស់ ! មនុស្សពូកែដូចឯង ទើបមិនឈឺខ្លួន ។ ឥឡូវយើង ចង់ដឹងថា តើនរណាប្រើឯងឱ្យមកសម្លាប់យើង ?

-បាទ !... បាទ !... គឺ... គឺ...

វាមិនហ៊ាននិយាយការពិត វាងាកទៅមិត្តវាម្នាក់ទាំងការភ័យញ័រ ។ នារីវដ្ត ងាកទៅបុរសនោះសួរថា :

-ឯងជាមេក្រុមមែនទេ ? ឥឡូវឆ្លើយនឹងសំនួរយើងមក ?

បុរសនោះឆ្លើយធ្វើព្រងើយថា :

-គឺក្រុមអំពិលអំពែក

នារីវដ្ដញញឹមងក់ក្បាល រួចទើបពោលដោយទឹកមុខមាំ :

-បាន !... យើងនឹងសុំលោកនាយកដោះលែងឯង ។

ភ្លាមនោះ លោកនាយកដែលនៅជិតនេះស្រាប់ បានឱ្យសញ្ញាទៅប៉ូលិស ។ ប៉ូលិសក៏ដោះលែងបុរសឈ្មោះ ជិនហ្គានោះឱ្យមានសេរីភាពវិញ។ វា ខំប្រឹងអរគុណនារីវដ្ដ និងអរគុណលោកនាយករួចចេញបាត់ទៅ។

នារីវដ្ដ ងាកមកម្នាក់ទៀតសួរថា :

-សំបុករបស់ក្រុមអំពិលអំពែកនៅឯណា ?

បុរសទី២នេះឈ្មោះ ប៉ង់ហ្គាម៉េ វាធ្វើធ្មឹងខិនមុខបន្តិចទើបឆ្លើយ:

-ខ្ញុំមិនហ៊ានប្រាប់កន្លែងទេ ព្រោះវិន័យក្រុមកំណត់ថា បើនរណា ប្រាប់ពីកន្លែងរបស់ក្រុម អ្នកនោះត្រូវស្លាប់ ។

មិនបង្អង់យូរ លោកនាយកឱ្យគេចងដៃចងជើងវាជាប់នឹងគ្រែ រួចយកខ្សែកាសមកពាក់លើក្បាលវា ចាប់ផ្ដើមសួរចម្លើយ តាមរយៈកុំព្យូទ័រ ។

ចម្លើយចម្លងមកលើក្រដាសប្រាប់ឱ្យដឹងថា ក្រុមអំពិលអំពែកជាក្រុមសម្ងាត់ដ៏ធំមួយរកស៊ីខុសច្បាប់ មានជួញដូរគ្រឿងញៀនជួញដូរស្ត្រីភេទ និងជួញដូរអាវុធជាដើម ។ ក្នុងសំណួរ នារីវដ្ដ ដែលសួររកទីតាំងរបស់វា បានឱ្យដឹងថា ទីស្នាក់ការរបស់ពួកវានៅក្នុងក្លឹបកំសាន្ត "ពពករសាត់" ជាបនល្បែងដ៏ធំមួយនៅម៉ាឡេ ។ ក្នុងសំណួរថា តើនរណាជួលពួកវាឱ្យមកសម្លាប់នារីវដ្ដ ?

ចម្លើយនៅលើក្រដាសបានឱ្យដឹងថា គឺក្រុមនាគខ្មៅជាអ្នកជួល ។ សព្វថ្ងៃក្រុមនាគខ្មៅក៏នៅក្នុងក្លឹបកំសាន្ត "ពពករសាត់" ដែរ ។

សួរចម្លើយរួច លោកនាយកក៏លែងបុរសទី២នេះទៅ ។ ឯនៅសល់ពីរនាក់ទៀតត្រូវជាប់ឃុំ ។

យប់នេះនៅក្លឹបកំសាន្តពពករសាត់ ក្រុមនាគខ្មៅកំពុងលក់ក្បាលអ្នកតាសិរីទ្ធឱ្យជនជាតិចិនកាត់ម៉ាឡេម្នាក់ ។ ក្រុមនាគខ្មៅ និងអ្នកទិញ តថ្លៃគ្នា យ៉ាងស្វិតស្វាញបំផុត :

-បាទ លោកនាយក្រុម សូមមេត្តាកុំកាត់ថ្លៃដល់ម្លឹងពេក !

-លោក សា ម៉េស ! ពីដើមមកលោកទិញអ្វីពីខ្ញុំ ពុំសូវសូញសាញពេកទេ ហេតុអ្វីថ្ងៃនេះត្រឹមតែប្រាំលានដុល្លា លោកធ្វើមើល តែថ្លៃណាស់អញ្ចឹង ?

ពេលនោះគ្នាវាម្នាក់ពោលមកកាន់លោកនាយក្រុម :

-ចៅហ្វាយ ! គាត់ប្រហែលពុំមែនជាលោក សាម៉េស ទេ ។

ដោយឃើញសញ្ញាភ្នែករបស់សហការីខ្លួន និងឃើញការញោចខ្លួន របស់លោកសាម៉េសពោលចំរឿងរបស់ខ្លួនបុរសម្នាក់ដែល គេហៅថាជានាយ ក្រុមក៏រលាស់វាចាថា :

-អូហូ ! នេះពិតជាលោកមេក្រុមក្លែងក្លាយមែនឬ ?

លោក សាម៉េស សើចរលាក់យ៉ាងស្រួលរួចទើបពោលថា :

-តើវាជាការចម្លែកណាស់ទៅឬដែលខ្ញុំហ៊ានឱ្យថ្លៃដល់ទៅបួនលានដុល្លារហើយលោកនៅថា ពុំសមរម្យទៀត ? ឬមួយលោកពុំចង់លក់ទេដឹង ?

លោកមេក្រុមពោលដោយទឹកមុខស្រស់ញញឹម :

-លើកនេះខ្ញុំគិតថា ខ្ញុំដាក់ថ្លៃមិនឱ្យលោកតទេ ។

-បាន ! បើអញ្ចឹងខ្ញុំព្រមទៅចុះ តើលោកត្រូវការប្រាក់សុទ្ធឬ ស្វែក ? ហើយតើខ្ញុំអាចទទួលរបស់នៅថ្ងៃណា ?

-ថ្ងៃស្អែកវេលាម៉ោងដដែល នៅទីនេះ ។ លោក សាម៉េស បំរុងដើរ ចេញ លោកមេក្រុមនាគខ្មៅនិយាយថា :

-ឈប់សិន ! ខ្ញុំសុំនាមប័ណ្ណរបស់លោកមួយសន្លឹក ។

លោក សាម៉េស នឹកក្នុងចិត្តថា ហ៊ឹះ ! ពួកអានេះស្អិតមែន ។ លុះលោកសាម៉េសហុចនាមប័ណ្ណទៅឱ្យលោកមេក្រុម នាគខ្មៅពោលថា :

-សុំទោសលោក សាម៉េស ពួកខ្ញុំបានជាប្រើអាកប្បកិរិយាពុំសមរម្យ ទៅលើលោកបន្តិចហើយ ព្រោះពួកខ្ញុំត្រូវតែផ្ទៀងផ្ទាត់ខ្លាចខូចការ ។ លោក សាម៉េស គិតក្នុងចិត្តថា អញក្លែងក្លាយ តែក៏ជាសំណាងល្អដែរ ដែលថ្នាក់លើឱ្យ នាមប័ណ្ណនេះមកមួយសន្លឹក បើពុំនោះទេច្បាស់ជាត្រូវពួកវាក្រេបួចពុំខាន ។ គិតរួចលោក សាម៉េស ពោលក្នុងមោទនភាព :

-ហាស់ ! ហាស់ ! លោកប្រយ័ត្នល្អណាស់ សូមលោកហែកនាម ប័ណ្ណនេះសាកមើល !

មេក្រុមនាគខ្មៅតបថា :

-គ្រាន់តែកាន់ ខ្ញុំដឹងថាមិនក្លែងក្លាយទៅហើយ ។

មេក្រុមពោលរួចក៏ហុចទៅឱ្យសហការីរបស់ខ្លួន :

លោក ហ្គ្លេរ៉ូ ទទួលយកនាមប័ណ្ណរបស់លោក សាម៉េសទៅហែក ។ ហែកមិនដាច់ក៏ហុចទៅឱ្យគ្នាវាម្នាក់ទៀត ។ ម្នាក់ក្រោយមានមាឌធំ កម្លាំងមាំ វាខំហែកយ៉ាងណាក៏ហែកមិនដាច់ ។ វានាំគ្នាពិនិត្យដោយឆ្ងល់ថា "ក្រដាស ធម្មតាហេតុអ្វីក៏ហែកមិនដាច់ " ។ ឃើញដូច្នេះមេក្រុមពន្យល់កូនចៅរបស់គេថា :

-នេះជាលោក សាម៉េស ពិតប្រាកដនាមប័ណ្ណរបស់លោកជានាមប័ណ្ណពិសេសហែកមិនដាច់ ហើយមានចំនុចមួយទៀត គឺកាលណាយកទៅដាក់ក្នុងកុំព្យូទ័រផ្ទាល់របស់លោក វានឹងដេញពន្លឺព្រាក់ៗ ជាការបញ្ជាក់ថាជានាមប័ណ្ណមិនក្លែងក្លាយ ។ លោក សាម៉េស ងក់ក្បាលពោលថា :

-សូមអរគុណលោកហើយ សូមលាហើយ ។

-បាទ ! សូមអញ្ជើញ សូមព្រះអាឡាប្រទានពរដល់លោក...

☆☆☆☆☆☆☆☆☆☆☆

យប់នេះដដែល ម៉ោងបួនរំលងអធ្រាត្រ នារីរដ្ឋ០៧១ ប្រើកូនសោរសាកល ចូលមកក្នុងបន្ទប់របស់ក្រុមនាគខ្មៅ ។ នាងយកនាឡិកាដក់ដៃលព្យួរនៅកនាងមកពិនិត្យមើល ឃើញទ្រនិចចង្អុលចូលទៅក្នុងទូដែក ។ នេះជានាឡិកាដក់វិទ្យាសាស្ត្រ ប្រើបានតែមួយមុខ គឺចង្អុលរកជាតិសរីទ្ធ ។ នាងដឹងថា ក្បាលអ្នកតាសរីទ្ធប្រាកដជានៅក្នុងទូដែកនេះ ។ ស្រស់ស្រី ក្រឡេកទៅសោរទូដែក គឺពុំមែនប្រើដោយកូនសោរទេ គេប្រើដោយម៉ាញ៉េទិចញីឈ្មោល ។ ធីតាហៀបនឹងលូកដៃទៅយកបន្តោងខ្សែ-ក វិទ្យាសាស្ត្រដែលមានធាតុម៉ាញ៉េ ទិចសំរាប់ដោះសោរនោះស្រាប់តែមានសម្លេងម៉ឺងម៉ាត់លាន់ឡើង :

-នាងឯងជានារីរដ្ឋ ០៧១ នោះមែនទេ ? ថ្ងៃនេះជាថ្ងៃអន្តរាយរបស់នាងហើយ ។ ក្នុងទូដែកនេះគ្មានក្បាលអ្នកតា ដែលនាងត្រូវរកនោះទេ ។ យើង នឹងទុកឱ្យនាងនៅទីនេះអត់បាយទាល់តែស្លាប់...

ស្រស់ស្រីខ្ញាក់សំដីថា :

-អូហូ ! ក្នុងពិភពចារកម្មគេហ៊ានពន្យាពេលទុកឱ្យខ្ញុំនៅទីនោះយូរថ្ងៃដែរឬ ?

សម្លេងឆ្លើយតបថា :

-ហេតុអ្វីទៅបានជាមិនហ៊ាន ?

-ហ៊ឺះ ! លោកល្ងង់ណាស់គេពិតជាដឹងថា ខ្ញុំនៅទីនេះ ។

-ហាស់ ! ហាស់ ! ហាស់ ! ទោះបីជាគេដឹងថា នាងនៅទីនេះ ក៏គេ មិនអាចជួយរំដោះនាងបានដែរ ។

នារីរដ្ឋ គិតថា ក្បាលអ្នកតាស័ក្តិសិទ្ធនៅក្នុងទូដែកនេះ តែពួកវាខំប្រឹងបញ្ឆោតនាងថា ទូដែកនេះគ្មានក្បាលអ្នកតាស័ក្តិសិទ្ធឡើយ នាងខំរកមធ្យោបាយ បញ្ឆោតពួកវា :

បើទូដែកនេះគ្មានក្បាលអ្នកតាស័ក្តិសិទ្ធទេ ខ្ញុំនិងអាចចាកចេញទៅវិញ បាន ។

សម្លេងសួរនាងថា :

-តើនាងទៅតាមណា ?

-ខ្ញុំមកតាមណាខ្ញុំទៅតាមហ្នឹងវិញ ។

-នាងយល់ច្រឡំហើយ ចំណីចូលដល់មាត់ខ្លាហើយ តើធ្វើម៉េចនឹង អាចរត់រួច ។

-លោកអាងលើអ្វី ?

-គឺផ្សែងពុល នេះនែ !

សំដីពុំទាន់ចប់ ផ្សែងពុលក៏បង្ហុយពេញបន្ទប់ ។ មាណវី នារីរដ្ឋ យកថ្នាំមួយគ្រាប់បង់ចូលក្នុងមាត់ ។ ផ្សែងពុលឡើងខ្លាំងពេញបន្ទប់ ទើបគេឃើញ បន្ទប់នេះមានលេចចេញនូវទ្វារសម្ងាត់មួយ រួចគេយកនាងទៅដាក់នៅលើគ្រែពូកដ៏ស្អាតអស្ចារ្យ ។ តាចាស់ម្នាក់ញញឹមបិទមាត់មិនជិត គាត់ដោះអាវធំចេញ ដោះក្រវាត់ក ដោះអាវដៃវែង នៅសល់តែអាវយឺត ។ គាត់ហៀបដោះខ្សែក្រវាត់ខោជាបន្ត តែដោយស្រេកឃ្លានពេក គាត់ក៏ហក់ទៅសង្គ្រប់នាង ។ គាត់ ថើបញក់ញ៉ីបណ្ដើរ គិតណ្ដើរថា : "ហ៊ឺ ! ក្លិនប្រហើរនៃស្រីក្រមុំ ដល់ម្ល៉ឹងផងន៍ ! អញទិញស្រីក្រមុំមួយខែមួយៗ តែគ្មាននាងណាមួយមានក្លិនប្រហើរដូចនាងនេះសោះ... ប្រសិនបើនាង ព្រមធ្វើជាប្រពន្ធចុងអញ អញនឹងឱ្យទ្រព្យសម្បត្តិទាំងអស់ទៅនាង..." ។

ពេលនេះតាចាស់ឮនាងដកដង្ហើមធំ ។ គាត់ភ្ញាក់រួចបែរជាត្រេកអរទៅវិញ ។ គាត់គិតបន្តថា : "បើចាំនាងដឹងខ្លួនទើបស្នេហាអញមានរសជាតិ អញនឹងប្រើស្នៀតប្លែកៗធ្វើឱ្យនាងទន់លោងសំពះអង្វរអញ" ។ តែដោយសារឃ្លានស្លឃាមគាត់ក៏ចាប់ឱបនាង ដោយអារម្មណ៍រវើរវាយ :

"ព្រះអាឡា ! ព្រះអង្គពិតជាជួយប្រទានពរដល់ខ្ញុំមែន ឱ្យតែបានរូប នាង ស្លាប់ទៅខ្ញុំបិទភ្នែកជិតហើយ..." ។

ស្រស់ធីតាប្រែខ្លួនឡើង បើកភ្នែកព្រឹមៗឃើញពិដានបន្ទប់ដ៏ទំនើប នាងបិទភ្នែកទៅវិញ ។ តាចាស់ក្រសោបអង្គកាយនាងទាំងមូលផ្អឹបមកក្នុង ដើមទ្រូងហាមាត់ត្របាក់បបូរមាត់ទាំងគូររបស់នាង ហាក់ចង់លេបរាងកាយនាងទាំងមូលតែម្ដង ។ នារីរដ្ឋ បណ្ដើរខ្សែភ្នែកមួយត្រួសដឹងជាក់សម្ភារៈនៅក្នុងបន្ទប់ ហើយនាងក៏ដឹងថា អាវក្រៅនាងត្រូវគេដោះចេញដែរ តែស្រស់ឆើតនៅវើរវាយលូកដៃចាប់បានអាវ ក្រៅរបស់ខ្លួនរួចឱបតាចាស់ដោយមិនដឹងខ្លួន ។ តាចាស់ភើតអារម្មណ៍ស្មានថា នាងកម្រើកកាមក៏បណ្ដោយតាមនាងដោយគិតថា : "ឱ ! អញអើយ ! អញនឹងធ្វើដំណើរទៅកាន់ស្ថានសួគ៌តឡូវនេះហើយ ! តើអញត្រូវអរគុណព្រះបែបណាទៅ ?..." ភ្លាមនោះវិប ! ហត្ថាដ៏រឹងដូចដែកថែបរបស់ នារីរដ្ឋ បង្វិលតាចាស់ ឱ្យផ្កាប់មុខដោយទាញដៃគាត់ទាំងពីរមកក្រោយចងនឹងអាវរបស់នាងយ៉ាងជាប់ណែន ។ មាណវីបង្វិលមុខគាត់មក វិញពោលយ៉ាងស្រស់ស្រាយ :

-ម៉េចលោកតា ! យើងអាចនិយាយគ្នាបានទេ ?

លោកតាធ្វើមុខស្មើឆ្លើយថា :

-នាងចង់និយាយពីរឿងអ្វី ?

ស្រស់ស្រីពោលដោយញញឹម :

-តើលោកតាជានរណា ?

-យើងជាមេក្រុមនាគខ្មៅ !

-បានអ្វីជាភស្តុតាង ?

-គឺត្រានៅក្នុងហោប៉ៅខ្ញុំ !

ធីតាលូកយកកូនត្រាតូចមួយប៉ុនម្រាមដៃ ពីក្នុងហោប៉ៅអាវ លោក តាតាមពិនិត្យមើល ស្រាប់តែឱប ! ជង្គង់លោកតាលេងខ្នងនាង ។ ស្រស់ស្រី ជ្រុលជំហរទៅមុខ ងាកមកវិញពោលថា :

-លោកតាភ្លើពេកហើយ ដៃជាប់ចំណងប៉ុណ្ណឹងហើយនៅហ៊ានសាក ល្បងជាមួយខ្ញុំទៀត ។

លោកតាឆ្លើយដោយញញឹម :

-គឺខ្ញុំធ្វើតេស្ត ដើម្បីចង់ដឹងថាតើនាងជា នារីវដ្ត០៧១ ពិតប្រាកដ ឬ ពុំមែនទេ ព្រោះខ្ញុំពុំដែលបានស្គាល់មុខនាងទាល់តែសោះ សូម្បីតែរូបថតក៏ពុំ ដែលឃើញដែរ ។

-លោកតាមិនបាច់ប្រើល្បិចជាមួយខ្ញុំទេ នេះនែចិត្តដែកថែប !

ផាំង ! ឈាមចេញពីមាត់លោកតា ធ្មេញគាត់ជ្រុះអស់ ៤-៥ ។ កណ្តាប់ដៃនាងពិតជាធ្ងន់មែន ។

បន្ទាប់មក មាណវីលើកលោកតាឱ្យអង្គុយស្រួលបួល ។ កល្យាណីស្រី ចិត្តដាច់រលាស់វាចាថា :

-កុំនិយាយច្រើន សោរបន្ទប់នៅឯណា ?

លោកតានៅអឹមអៀនស្ងៀមឈឹង ។ ផាំង ! ថៃមមួយដៃចំថ្គាម លោកតាដួលខ្ពោក ! ទៅលើកំរាលឥតឈាមហូរជោកអាវ ។ លោកតាដឹងខ្លួន ឡើងវិញ សំឡឹងនាងក្នុងកែវភ្នែកចងអាឃាដ ។ នារីវដ្ត ០៧១ លើកលោកតា ឱ្យអង្គុយលើពូកវិញរួចសួរចម្លើយរន្ថើន :

-ម៉េច ! នៅចាំដល់ណាទៀត ?

លោកតាពោលថា :

-ចំពោះខ្ញុំ ! នាងពុំអាចប្រើធមិក្តៅបានទេ ?

មាណវី គិតថា ពេលនេះជាពេលប្រថុចញ៉ុច មិនអាចអែអង់បានឡើយ ។ វានិយាយជាការពិត "មិនអាចប្រើធមិក្តៅបានទេ " ។ ប៉ុន្តែធ្វើម៉េច នឹងមានកុំព្យូទ័រសួរចម្លើយវា ? បើចាប់វាយកទៅជាការលំបាកណាស់ ព្រោះទីនេះជាសំបុករបស់ពួកវា ។ ស្រស់ធីតាកំពុងគិតមិនចេញស្រាប់តែតាចាស់ យកកែងជើងជាន់ចំក្បាលចម្លាក់នៅលើក្បាលគ្រែទ្វារបន្ទប់សម្ងាត់ក៏បើកឡើង តាមពិតក្បាច់ចម្លាក់នៅលើក្បាលគ្រែជាគន្លឹះឱ្យសញ្ញាអាសន្នដល់កូនចៅគាត់ ។ ពេលនោះបុរស៤នាក់ ប្រដាប់ដោយអាវុធទំនើប១បានចូលមកភ្ជង់នាង ។ ព្រមជាមួយនេះនាឡិកាដៃរបស់នារីវដ្ត ក៏ឱ្យសញ្ញាថាសហការីរបស់ខ្លួនបានមកដល់ទីនេះហើយ ។ ស្រស់ស្រីខំប្រមូលអារម្មណ៍ លើកកម្លាំងចិត្តខ្លួនឯងថា "យើងទាល់ច្រកមែន តែយើងមិនអស់សង្ឃឹមទេ... អ្វីដែលគួរឱ្យស្តាយនោះ គឺក្បាលអ្នកតាសិរិទ្ធនៅក្នុងទូដែកនេះ ដូច្នេះយើងពិតជាមានមធ្យោបាយរំដោះយកបាន " ។ កំពុងតែគិត ស្រាប់តែបុរសម្នាក់លើកកាំភ្លើងបុកនាង ធ្វើឱ្យនាងជ្រុលទៅមុខពីរជំហាន ។ បុរសម្នាក់ស្រាយចំណងចៅហ្វាយ រួចក៏យកចំណងនោះមកចងដៃនាងក្រពាត់ទៅក្រោយ ។ ពួកវាហៀបរៃនាងមួយស្ទាយកាំភ្លើង ត្រូវចៅហ្វាយឃាត់ ។ តាចាស់បើកទូយកខ្សែមួយចង្វាយមកចងជើងនាងទាំងពីរភ្ជាប់ទៅគ្រែ ។ រួចគាត់កាត់ខ្សែមួយកំណាត់មកចងដៃទាំងពីររបស់នាងភ្ជាប់ទៅគ្រែក្បាលដំណេក ។ លុះចងហើយស្រួលបួលគាត់ឱ្យសញ្ញាភ្នែក កូន ចៅទាំង៤ ក៏គេចបាត់ទៅ ។ ទ្វារសម្ងាត់ក៏បិទមកវិញ ។

តាចាស់ប្រាកដជាល្មោភកាមមែន ត្រូវរបួសហើយនៅមិនខ្វាក់ចោលចំណីឆ្ងាញ់ទៀត ។ គាត់យកទឹកសុទ្ធមកលាងឈាមមាត់រួចក៏ឡើងពោបពីលើនាង ។ នារីវដ្ត ខឹងណាស់ ! នាងពុំមែនខឹងនឹងគាត់ចាប់នាងចងទេ តែខឹងនឹងគំនិតព្រើលរបស់មនុស្សចាស់ ។ បើកុំតែពេលនេះនាឡិកាដៃរបស់នាងឱ្យសញ្ញាថា សហការីរបស់នាងមកដល់ទីនេះ ម្ល៉េះសមនាងប្រើល្បិចស្នេហ៍ ធ្វើឱ្យតាចាស់នេះក្អួតឈាមម្តងទៀតពុំខាន ។

ភ្លាមនោះទ្វារបន្ទប់របើកឡើង លោក ក-៥៣ សហការីរបស់នាងនាំ ប៉ូលិសម៉ាឡេមួយក្រុមចូលមក ។ ដោយទាល់ច្រកតាចាស់ត្រូវប៉ូលិសចាប់រឹតខ្នោះ។ ភ្លាមនោះដែរ ទ្វារសម្ងាត់ក៏របើកឡើង ប៉ូលិសម៉ាឡេបានបាញ់រះប្រាវ! ប្រាវ ! ធ្វើឱ្យពួកចោរស្លាប់អស់៤-៥នាក់។ ក្រុមប៉ូលិសសំរុកចូលទៅបន្ទប់មួយទៀតតាមទ្វារសម្ងាត់ ។ ស្នូរប្រយុទ្ធលាន់ឡើងយ៉ាងគគ្រឹកគគ្រេង ។ ក-៥៣ ម្ចីម្ចាស្រាយចំណងឱ្យចៅហ្វាយ ។ រួចពីចំណងស្រស់ធីតាពោលសួរ :

-តើខាងប៉ូលិសមានគ្នាច្រើនទេ ?

លោក ក-៥៣ ឆ្លើយថា :

-បាទ ! ច្រើនណាស់ មិនអីទេ !

ប៉ូលិស ៤-៥នាក់ នាំតាចាស់មេក្រុមនាគខ្មៅចេញមកក្រៅបន្ទប់ ស្រាប់តែប្រាវ ! ប្រាវ ! ស្លាប់ទាំងអស់ ។ បាញ់រួចពួកចោររំដោះមេក្រុមរបស់វាទៅបាត់ ។ នារីរដ្ឋ និង ក៥៣ អែបខ្លួនទៅនឹងមាត់ទ្វារខាងក្នុង ទើបពុំមានគ្រោះថ្នាក់ ។ នៅបន្ទប់ម្ខាងស្នូរផ្ទុះអាវុធក៏ត្រូវបានបញ្ចប់ ។ នារីរដ្ឋ និងនាង ខ្សឹបប្រាប់ ក-៥៣ ថា : "ក្បាលអ្នកតាសិរិទ្ធនៅក្នុងទូដែក" ។ ពេលនោះក្រុម ប៉ូលិសម៉ាឡេ ក៏បន្ថែមកម្លាំងជាង១០នាក់មកទៀត ។ នារីរដ្ឋ ខ្សឹបប្រាប់ ប្រធានក្រុមប៉ូលិស។ ប្រធានក្រុមងក់ក្បាលយល់ព្រម ។ តែទ្វារបន្ទប់បិទជិតទៅហើយ ។ នារីរដ្ឋយកសោរចាក់សាកបើកទ្វារបន្ទប់ ។ រួចស្រស់ស្រីយកបន្តោងខ្សែក ដែលមានធាតុម៉ាញ៉េទិចញី-ឈ្មោលមកដោះសោរទូដែក ។ អស្ចារ្យមែន ! ទ្វារទូដែកបើកឡើង ស្រាប់តែស្រស់ស្រីផ្ទុះសំដីថា :

-ពុទ្ធោ ! ពួកវារំដោះយកក្បាលអ្នកតាបាត់ទៅហើយ !

ស្រស់ធីតា សម្រួលបានអារម្មណ៍នឹងនរួចក៏រួមដំណើរជាមួយក្រុម ប៉ូលិសចាកចេញពីសណ្ឋាគារ "ពពករសាត់ " ដោយនាំខ្មោចប៉ូលិសជិត ១០នាក់ មកជាមួយផង ។

## ជំពូកទី៩
## លក់ក្បាលអ្នកតាសិរិទ្ធ

ជាការពិត ពួកចោរអាចយកយុទ្ធសាស្ត្រសង្គ្រាមមកប្រើការមានប្រសិទ្ធភាពណាស់ ។ ទីកន្លែងដែលមានគ្រាប់កាំភ្លើងធំធ្លាក់ហើយយើងទៅ ពួនកន្លែងហ្នឹងចុះ ពុំមានគ្រាប់កាំភ្លើងធ្លាក់មកចំកន្លែងហ្នឹងទៀតទេ ។

ថ្វីបើបន្ទប់សម្ងាត់របស់ក្រុមនាគខ្មៅត្រូវប៉ូលិសដឹងក៏ពួកនេះនៅតែ ប្រើបន្ទប់នេះសម្រាប់ការលក់ក្បាលអ្នកតាសិរិទ្ធដដែល ។ យប់នេះវេលាម៉ោង ដដែល លោក សាម៉េស អ្នកទិញក្បាលអ្នកតាសិរិទ្ធបានមកជួបមេក្រុមនាគខ្មៅ តាមពេលវេលាដែលបានណាត់ ។ នៅឯក្រៅសណ្ឋាគារក៏ដូចជានៅក្នុងសណ្ឋាគារដែរ ក្រុមប៉ូលិសសម្ងាត់ម៉ាឡេ វាយគ្នាដូចស្រមោច តាមដានរកមើលសកម្មភាពរបស់ក្រុមនាគខ្មៅ ។

ក្លឹបកំសាន្ត ពពករសាត់ប្រព្រឹត្តិទៅយ៉ាងហ៊ឹកហ៉ាក់ដដែល ហាក់ដូច ជាកាលពីព្រឹកមិញនេះ គ្មានរឿងហេតុអ្វីកើតឡើងសោះ ។ នេះបានចំជាការ វិវត្តន៍របស់ខួរក្បាលមនុស្សមែន គេបាញ់គ្នាងាប់អស់មនុស្សជាង ១០នាក់ ហើយនៅតែមានមនុស្សមកលេងល្បែងពេញៗដដែល ។

ប៉ូលិសសម្ងាត់បណ្ដាក់គ្នាបន្តឃ្លាំមើលបន្ទប់របស់ក្រុមនាគខ្មៅ ប៉ុន្តែ ក្នុងបន្ទប់ក្រុមនាគខ្មៅ លោក សាម៉េស កំពុងប្រគល់លុយឱ្យមេក្រុមនាគខ្មៅ ចំនួន ៥លានដុល្លារអាមេរិច ។ ក្រោយពីការពិនិត្យមើលស្រួលបួលហើយ មេក្រុមនាគខ្មៅក៏ប្រើប្រអប់ម៉ាញ៉េទិចញី-ឈ្មោលដ៏តូចមួយបើកទូដែកឡើង ឃើញក្បាលអ្នកតាសិរិទ្ធ នៅក្នុងទូដែកនេះ ។ មែន ! កាលពីយប់មិ្សល ក្រុម នាគខ្មៅបានយកក្បាលអ្នកតាសិរិទ្ធចេញពីក្នុងទូដែក ព្រោះវាជឿថា នារីវដ្ត ០៧១ ប្រាកដជាអាចមានមធ្យោបាយបើកទូដែលរបស់វា ។ លុះភ្លឺឡើងវាក៏ យកក្បាលអ្នកតាសិរិទ្ធទៅដាក់ក្នុងទូដែកវិញ។ ក្រុមនាគខ្មៅធ្វើដូច្នេះបាន ដោយសារវាប្រើផ្លូវសម្ងាត់ច្រើនជាន់ ។ ក្រុមប៉ូលិស សម្ងាត់យាមទល់ភ្លឺពុំអាច ដឹងថានៅក្នុងបន្ទប់មានសកម្មភាពអ្វីឡើយ ។ ក្រោយពីលើកយកក្បាលអ្នក តាសិរិទ្ធ មកដាក់នៅលើតុ បង្ហាញលោក សាម៉េស ។ លោក សាម៉េសក៏យកប្រអប់វិទ្យាសាស្ត្រដ៏តូចមួយមកដាក់នៅលើក្បាលអ្នកតា ដើម្បីពិនិត្យមើលថា តើក្បាលអ្នកតាសិរិទ្ធពិប្រាកដមែន ឬជាសិរិទ្ធក្លែងក្លាយ ។

លុះពិនិត្យរួច លោកសាម៉េស ងក់ក្បាលញញឹមស្រស់ :

-ដូចដែលខ្ញុំបានគិតមែនថា លោកជាមនុស្សរកស៊ីទៀងត្រង់រៀង រហូត ដូចកាលខ្ញុំទិញរបស់ពីលោកលើកមុនៗអញ្ចឹង ។

មេក្រុមនាគខ្មៅពោលដោយសប្បាយរីករាយ :

-អូ ! ហូ ! ខ្ញុំគ្មានវាចានឹងថ្លែងទេ តែខ្ញុំសូមអរគុណលោកណាស់ ដែលលោកសរសើរខ្ញុំ ហើយខ្ញុំសង្ឃឹមថា លោកនឹងបញ្ជាទិញនូវអ្វីផ្សេងៗទៀត ដែលលោកត្រូវការ ។

ចប់វាចា អ្នកទាំងពីរចាប់ដៃគ្នាយ៉ាងស្រស់ញញឹម ។ ភ្លាមនោះ ទ្វារ សម្ងាត់បើកឡើង ។ លោកសាម៉េស លើកក្បាលអ្នកតាសិរិទ្ធដាក់ក្នុងថង់ធ្វើ អំពីស្បែកដែលជាថង់សំរាប់យុវជនធ្វើទេសចរណ៍ ។ ពួកក្រុមនាគខ្មៅបាននាំ លោក សាម៉េស ដើរក្រវិចក្រវៀនប្រហែល ៥នាទី ក៏ឡើងតាមទ្វារសម្ងាត់មួយ ។ ទីនេះជាផ្ទះលក់ខោអាវទំនើបៗមកពីបរទេស ។ លោក សាម៉េស ស្ពាយថង់ ស្បែកចេញពីផ្ទះលក់ខោ-អាវ ជាមួយភ្ញៀវដែលចូលទិញសំលៀកបំពាក់នៅហាងនេះ ។

តើមាននរណាដឹងថា ក្នុងថង់នេះមានក្បាលអ្នកតាសិរិទ្ធ ដែលជា មរតករបស់ខ្មែរ ? ។ មែន ! ពិតជាគ្មាននរណាដឹង ។

ប៉ុន្តែប្រការគួរឱ្យអស្ចារ្យនោះគឺ នារីវដ្ត ០៧១ បានដឹងលេខទូរស័ព្ទ របស់ក្រុមនាគខ្មៅ ពីប៉ូលិសម៉ាឡេដែលសហការជាមួយនាង ។ ស្រស់ស្រី ទូរស័ព្ទទៅកាន់មេក្រុមនាគខ្មៅថា :

-អាឡូ ! សួស្តីបង ! បងសុខសប្បាយទេ ឬ ?

សម្លេងពីខ្សែម្ខាងសួរមកនាងថា :

-សួស្តី ! នាងជានរណា ?

ស្រស់ធីតាឆ្លើយតបវិញ :

-អូ ! ហូ ! ម៉េចក៏បងឆាប់ភ្លេចម្ល៉េះ ! គឺអូនជានារីដែលបងទ្រោបពី លើនោះអី... ម៉េច ! ចាំបានទេ ?

-បាទ ! នឹកឃើញហើយ ឥឡូវនាងមានការអីហ្នឹង ?

-ម៉េច ! ប្រែចិត្តលែងស្រឡាញ់អូនហើយឬ បានជាហៅអូនថា "នាង" ទៅវិញ ?

គ្រាន់តែដឹងថា នារីវដ្ត ០៧១ តាចាស់មេក្រុមនាគខ្មៅខឹងណាស់ ។ តែលុះឮនាងនិយាយទន់ផ្អែមទៅរកគាត់ដោយប្រើពាក្យថា "អូន-អូន" គាត់ក៏ ប្រែសម្លេងទន់ផ្អែមមកវិញ :

-រដ្ឋអូន ! ដួងព្រលឹងជីវិតបង ! បងស្រឡាញ់អូនណាស់ បងនឹងឱ្យ គេយកលុយចំនួន១ម៉ឺនដុល្លារទៅឱ្យអូន តើអូនព្រមទទួលទេ ។

ស្រស់វល័ក្ខណ៍ បញ្ជោក់ជូនគាត់ថា :

-បង ! ៥លានដុល្លារ ! បងឱ្យអូនមួយម៉ឺនហាក់ដូចជាតិចពេកទេដឹង ?

គ្រាន់តែឮ៥លានដុល្លារ មេក្រុមនាគខ្មៅញ្ញោចខ្លួនគិតថា "យី !

ម៉េចក៏នាងដឹងថា អញមាន៥លានដុល្លារ... ហ៊ឺ! ប្រហែលជានាងដឹងពីរឿងលក់ ក្បាលអ្នកតានោះហើយ... នេះបានចំជានារីខ្មែរដ៏អស្ចារ្យមែន" ដោយនឹក ឃើញក្លិនខ្លួនដ៏ប្រហើររបស់នាង តាចាស់ភ្លេចរឿងអ្វីៗទាំងអស់ គាត់នឹកឃើញ តែម្យ៉ាង គឺតើធ្វើយ៉ាងណាដើម្បីឱ្យបានលូនលេង នៅលើទ្រូងនាង ។ តាចាស់ ឆ្លើយវិញយ៉ាងស្រទន់ថា :

-វដ្ដអូន! អូនចង់បានប៉ុន្មានក៏បងឱ្យដែរ ឱ្យតែអូនព្រមស្រឡាញ់បង ! បងនឹងឱ្យអូនទាំងប្រាំលានដុល្លារ... វដ្ដអូន ! ព្រមទៅណា !

ស្រស់វល័ក្ខណ៍តបវិញដោយធ្វើជាបេះដូងរញ្ជួយ :

-អ៊ូយ ! មែនឬបង ! បើប្រាកដមែន អូនព្រមហើយ តើបងឱ្យអូន ជួបបងនៅឯណា ?

-ទេ ! ទេ ! បងមិនហ៊ានជួបអូនឥឡូវនេះទេ គឺអូនត្រូវទៅជួបបង នៅហុងកុង អូនទៅដល់ទីនោះ បងនឹងឱ្យគេទៅទទួលអូននៅព្រលានយន្តហោះ ហើយយើងនឹងរស់នៅជាមួយគ្នានៅប្រទេសណាក៏បាន ។

-អញ្ចឹង ! តើបងឱ្យលុយអូនប៉ុន្មាន ដើម្បីជាស្ពានចម្លងស្នេហ៍យើង ?

តើអូនត្រូវការប៉ុន្មាន ?

-ចាំ ! ហាសិបម៉ឺន !

គ្រាន់តែឮហាសិបម៉ឺន តាចាស់មានរំញោចថា : "ហ៊ឺ ! ចារនារី សា ហាវណាស់ ! នារីណាក៏ដូចជានារីណាដែរ !... នាងប្រាកដជាដឹងថា អញបាន ហាសិបម៉ឺនដុល្លារ ដោយសារសម្លាប់អាគ្រឹះ ដែលវាក្បត់អញ... ឥឡូវដើម្បី សេចក្ដីស្នេហាក្នុងជីវិតចុងក្រោយរបស់អញនេះ អញឱ្យវាហា សិបម៉ឺននេះចុះ ប្រសិនបើវាបោកប្រាស់អញ ចាត់ទុកថាដាក់ទានឱ្យវាទៅចុះ..." ។ គិតរួច តា ចាស់ក៏ឆ្លើយថា :

-វដ្ដអូន ! អញ្ចឹងបងឱ្យគេយកលុយទៅឱ្យអូនណាំ !... តើអូនត្រូវ ទៅទទួលលុយនៅឯណា ?

-គឺនៅផ្ទះលក់សំលៀកបំពាក់ អ៊ិនឌីយ៉ា ណាហាវ !

គ្រាន់តែឮពាក្យ "អ៊ិនឌីយ៉ា ណាហាវ " តាចាស់ភ្ញាក់ក្នុងចិត្តថា : "ប៉ៃ ! ជាន់ខ្មោចក្រមុំ ! នាងដឹងថា អ៊ិនឌីយ៉ា ណាហាវ ជាហាងរបស់អញឬ ? តែ ណ្ហើយចុះ យូរនឹងឆាប់អញគង់តែលក់ហាងនោះដដែល ឱ្យវាទៅតាមដំណើរ ចុះ..." ។ គិតរួចតាចាស់ឆ្លើយថា :

អញ្ចឹងអូនអាចមកយកល្ងាចនេះ នៅវេលាម៉ោង ៧.០០... តែបើ អូនក្បត់បង ប្រយ័ត្នដូចករណីអាគ្រឹះ ណាំ !...

-ចាំ ! រឿងនេះអូនដឹងច្បាស់ហើយ ! អូនសូមអរគុណបងទុកជាមុន ! អូនសូមថើបបងពីចម្ងាយ ។

## ជំពូកទី១០
## ក្រុមចចានសំបុកនាគខ្មៅ

មែន! អ្វីៗទៅតាមសម្រួលទាំងអស់ ស្រស់ធីតាកញ្ញា នារីវដ្ដ បានទទួលលុយចំនួនហាសិបម៉ឺនដុល្លារពីបុរសម្នាក់ ដែលចូលមកទិញខោ អាវនៅហាងលក់សំលៀកបំពាក់ អ៊ិនឌីយ៉ា ណាហាវ ។ ស្រស់ជីវ៉ាលើកហត្ថាទទួលយក កាដូ ដែលមានលុយនៅក្នុងនោះ រួចនាងហុចទៅឱ្យបុរសវិញ នូវកូនសំបុត្រតូចមួយបិទជិតផ្ញើទៅឱ្យមេក្រុមនាគខ្មៅ ។ ក្រោយពីបានទទួលលិខិតរបស់នារីវដ្ដ តាចាស់អរកខិបកខុបប្រញាប់លាសំបុត្រមើល ។ លិខិតជាអក្សរអង់គ្លេស៤-៥ បន្ទាប់ មានខ្លឹមសារថា: "បងសម្លាញ់ ! អូនអរគុណ បងហើយ ដែលបងបាន គោរពតាមពាក្យសន្យា ! តែសូមបងអភ័យទោសឱ្យអូនផង យើងទាំងពីរពុំ អាចជួបគ្នាទេ ព្រោះបងបានសាងតែអំពើអាក្រក់ ប៉ូលិសម៉ាឡេបានតាមដានបងជាប់ជានិច្ច ទោះបងពួនទៅក្នុងរូងនៃហាងលក់សំលៀកបំពាក់ ឬបងទៅដល់ទីណា ក៏គេដឹងដែរ កូនចៅជំនិតរបស់បងបីនាក់ គឺលោក ជិនហ្គាលោក ប៉ង់ ហ្គាម៉េ និងលោក ហ្គ្លេរ៉ូ ត្រូវប៉ូលិស ចាប់ខ្លួនហើយមែនទេ ?

មួយសន្ទុះក្រោយមកកូនចៅរត់មកជិតចៅហ្វាយ ឱនខ្លួនរាយការណ៍ ថា :

-បាទ ! ចៅហ្វាយ បង១ទាំងបីត្រូវប៉ូលិសចាប់បាត់ទៅហើយ មេ ក្រុមបញ្ជាថា :

-ឥឡូវយើងមិនត្រូវធ្វើសកម្មភាពអ្វីទាំងអស់ គ្នាយើងនៅសល់តែ ៧ នាក់ ហាមមិនឱ្យចេញពីក្នុងរូងឡើយ យើងរស់នៅតែក្នុងរូងរហូត យើងមិនត្រូវចាញ់ល្បិចវាយស្ទាបង្អើលពស់របស់ក្រុមប៉ូលិសទេ ។

នៅក្នុងសាលប្រជុំនៃនាយកដ្ឋានប្រឆាំងឧក្រិដ្ឋកម្មដោយមានវត្តមាននារីវដ្ត ០៧១ និងលោក ក-១២ ចារបុរសខ្មែរ ចូលរួមប្រជុំផងលោកនាយក មានប្រសាសន៍ថា :

-ជាបឋមខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ នារីវដ្ត និង លោក ក-១២ ដែលបានសហការជាមួយប៉ូលិសយើងកំចាត់អំពើឧក្រិដ្ឋកម្មនៅ លើទឹកដីនៃប្រទេសម៉ាឡេ ជាពិសេសខ្ញុំសូមសរសើរដោយស្មោះនូវទឹកចិត្តហ៊ាន លះបង់អាយុជីវិតរបស់លោក ក-១២ ដែលហ៊ាន ក្លែងខ្លួនជា លោក សាម៉េស ទៅទិញបានក្បាលអ្នកតាសិរិទ្ធមកវិញ ។

លោកនាយកបង្អង់បន្តិច រួចងាកទៅញញឹមដាក់នារីវដ្ត និងលោក ក-១២ ទើបបន្តថា :

-ថ្ងៃស្អែកនេះ ដោយមានលិខិតអនុញ្ញាតពីស្ថាប័នតុលាការ យើងនឹងប្រើគ្រប់មធ្យោបាយទាំងអស់ ដោយមានកម្លាំងប្រដាប់អាវុធជួយការពារផងចូលទៅឆែកឆេរបន្ទប់នៅក្លឹបកំសាន្ត ពពករសាត់ និងផ្ទះលក់សំលៀកបំពាក់ អ៉ិនឌីយ៉ា ណាហារ ដើម្បីសំរុកចូលទៅក្នុងរូងក្រោមដីរកចាប់មេក្រុមនាគខ្មៅ ។

លោកនាយកបង្អង់បន្តិច ញញឹមដាក់ នារីវដ្ត ដោយពោលថា :

-ថ្ងៃស្អែកនេះ យើងមិនហ៊ានរំខានអ្នកនាង និងលោក ក-១២ ទេ ។

នារីវដ្ត០៧១ សំដែងទឹកមុខរីករាយ មានវាចាថា :

-ចាំ ទោះបីជាយ៉ាងណាក៏នាងខ្ញុំត្រៀមខ្លួនជានិច្ច រង់ចាំសហការជា មួយលោកនៅពេលណាដែលលោកត្រូវការ ។

លោកនាយកងក់ក្បាលតប :

-បាទ សូមអរគុណអ្នកនាងហើយ ។

ក្រោយពីការសំណេះសំណាលគ្នាបន្តិចមក អង្គប្រជុំក៏ត្រូវចប់ ។ ស្អែកឡើងក្រុមសមត្ថកិច្ចចម្រុះ ក៏ត្រូវទៅឆែកឆេរតាមការណាត់ ។ ក្រុម សមត្ថកិច្ចចាប់បានក្រុមនាគខ្មៅទាំង ៧នាក់ ។ ឯប្រាក់ ៥លានដុល្លារ ក៏រក ឃើញនៅជាមួយពួកវាដែរ ។

**ចប់ដោយបរិបូរណ៍**